# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ ទឹម ធាន ភេទប្រុស អាយុ៥៦ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ "យោធាក្នុងវរសេនាធំ៨២"

## មានស្រុកកំណើត នៅភូមិព្រែកដូង ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្ដាល

## សព្វថ្ងៃរស់ភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ សោម ប៊ុនថន

## ០១:៥២:៥៦

## ៤៥ទំព័រ

ថនៈ ចឹងជីបូនខ្ញុំសូមសួរឈ្មោះពូ ពូឈ្មោះអីដែរពូ?

ធានៈ បាទ! ខ្ញុំឈ្មោះ ទឹម ធាន ។

ថនៈ ឈ្មោះ ទឹម ធាន!

ធានៈ បាទ!

ថនៈ ពូ! មានឈ្មោះអីហៅក្រៅហ្នឹងទៀតទេ?

ធានៈ អត់មានទេ!

ថនៈ ពូអាយុប៉ុន្មានហើយលោកពូ?

ធានៈ អាយុ៥៦ហើយ ។

ថនៈ ពូ មានស្រុកកំណើតនៅភូមិឃុំអីដែរលោកពូ?

ធានៈ ខ្ញុំនៅភូមិព្រែកដូង ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

ថនៈ ភូមិព្រែកដូង ឃុំកំពង់ស្វាយ ស្រុក?

ធានៈ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

ថនៈ ពូមានបងប្អូនប៉ុន្មាននាក់ពូ?

ធានៈ ខ្ញុំបច្ចុប្បន្ននេះមានបងប្អូន៩នាក់ ។

ថនៈ ពូកូនទីប៉ុន្មាន?

ធានៈ ខ្ញុំកូនទី៣ ។

ថនៈ កូនទី៣?

ធានៈ បាទ!

ថនៈ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ធានៈ ប្រុស៧ ស្រី២ ។

ថនៈ ពូអាចរៀបរាប់ឈ្មោះ បងប្អូនរបស់ពូបានទេ? កូនទីមួយឈ្មោះអីគេ?

ធានៈ ធាទីមួយឈ្មោះ ទឹម ឡុង ។

ថនៈ ទឹម ឡុង?

ធានៈ បាទ!

ថនៈ ស្រី ឬក៏ប្រុស?

ធានៈ ស្រី!

ថនៈ គាត់នៅរស់ទេ?

ធានៈ នៅ!

ថនៈ នៅរស់នៅឯណា?

ធានៈ បច្ចុប្បន្ននៅភូមិព្រែកដូង គៀនស្វាយដដែរ ឃុំដដែរ ផ្លាស់តែភូមិទេ ប៉ុនឃុំនៅដដែរ ស្រុកនៅដដែរ ។

ថនៈ ចុះកូនទី២?

ធានៈ ទី២ឈ្មោះ ទឹម ធន់ ។

ថនៈ «ធ» និង «ប់»?

ធានៈ បាទ!

ថនៈ ស្រី ឬក៏ប្រុស?

ធានៈ ប្រុស ។

ថនៈ គាត់នៅរស់ដែរ?

ធានៈ នៅរស់ដែរ ។

ថនៈ នៅគៀនស្វាយ?

ធានៈ បាទ!

ថនៈ ទី៣?

ធានៈ ទី៣ គឺរូបខ្ញុំ ។

ថនៈ ចុះទី៤?

ធានៈ ទី៤ ឈ្មោះ ទឹម ធឿន ។

ថនៈ ធឿន?

ធានៈ បាទ!

ថន៖ គាត់នៅរស់ដែរ?

ធាន៖ នៅរស់ ។

ថន៖ នៅគៀនស្វាយដែរ?

ធាន៖ បច្ចុប្បន្នមកនៅឯភ្នំពេញគីឡូ៦ ។

ថន៖ ទី៥?

ធាន៖ ទី៥ឈ្មោះ ទឹម ផុល ។

ថន៖ គាត់នៅរស់ដែរ?

ធាន៖ បាទ! នៅរស់ដែរ ប៉ុន្តែបច្ចុប្បន្ននៅត្រពាំងប្រាសាទ ។

ថន៖ គាត់ធ្វើអីដែរពូ?

ធាន៖ គាត់អាជីបរកស៊ី លក់ដូរ បន្លែ ដូចជាម្ហូបអាហារ ។

ថន៖ ទី៦?

ធាន៖ ទី៦ ឈ្មោះ ទឹមថៃ ។

ថន៖ ទឹម ថៃ! គាត់នៅរស់ដែរ?

ធាន៖ នៅរស់ប៉ុននៅឯស្រុកភូមិដដែរ ។

ថន៖ រស់នៅគៀនស្វាយ ។ គាត់ដែរមកលេងនៅទីនេះដែរទេលោកពូ បងប្អូននៅគៀនស្វាយ?

ធាន៖ មក! មកការក្មួយការអី ម្តាយខ្ញុំក៏មកការចៅគាត់ដែរ ។

ថន៖ ទី៧ លោកពូ?

ធាន៖ ទី៧ ឈ្មោះ ទឹម ម៉ៅ ។

ថន៖ គាត់រស់ដែរ?

ធាន៖ រស់ដែរ ។

ថន៖ នៅឯណាលោកពូ?

ធាន៖ ហ្នឹងនៅភូមិកំណើតដែរ ។

ថន៖ គៀនស្វាយ ។

ធាន៖ បាទ!

ថន៖ ទី៨?

ធាន៖ ទី៨ ឈ្មោះ ទឹម ស្រីលីន ។

ថន៖ ទឹម ស្រីលីន ។ អាហ្នឹងស្រី?

ផានៈ បាទ!

ថនៈ គាត់នៅរស់ដែរ?

ផានៈ នៅរស់ ។

ថនៈ នៅកៀនស្វាយពូ?

ផានៈ បាទ!

ថនៈ ទី៩ កូនពៅ?

ផានៈ ទឹម មឿន ។

ថនៈ ស្រីដែរអីលោកពូ?

ផានៈ ប្រុស ។

ថនៈ នៅណាដែរពូ?

ផានៈ នៅភូមិកំណើតដែរ ។

ថនៈ ហ៊ូមិញ ថាស្រី២នាក់អីពូ?

ផានៈ បាទស្រី២ ។ បងទី១នេះមកទី៨ ស្រី លីន ។

ថនៈ លីន ស្រី!

ផានៈ បាទ!

ថនៈ ចុះឪពុកម្តាយរបស់ពូនៅរស់ទេ?

ផានៈ គាត់ស្លាប់ហើយនៅតែម្តាយ ។

ថនៈ ឈ្មោះអីវិញពូ?

ផានៈ ឪពុកឈ្មោះ តាំង ។

ថនៈ ត្រកូលគាត់?

ផានៈ ត្រកូលគាត់អត់មានដែរ ។

ថនៈ គាត់ស្លាប់នៅឆ្នាំប៉ុន្មានពូ?

ផានៈ គាត់ស្លាប់នៅក្នុងឆ្នាំ ១៩៩៨ ។

ថនៈ ម្តាយឈ្មោះ អីវិញ?

ផានៈ យឹម ឡាយ ។

ថនៈ គាត់រស់បច្ចុប្បន្ននៅណាវិញ?

ផានៈ គាត់នៅភូមិព្រែកទំបន់ ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

ថន: គាត់អាយុប៉ុន្មាន សព្វថ្ងៃ?

ធាន: សព្វថ្ងៃអាយុចូលជិត៨០ ហើយទេដឹង ។

ថន: ឪពុកពូស្លាប់៩៨ ស្លាប់ដោយសារអ្វី?

ធាន: ដោយសារជំងឺរោគា គាត់ចាស់ហើយ ។

ថន: ពីមុន ពូរៀនសូត្រដល់ណាដែរ ពូកាលពីក្មេង?

ធាន: ខ្ញុំពីសង្គមដែលជំនាន់ ១៦ឆ្នាំ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១២ ថ្នាក់ទី១១ចុះ ក៏រដ្ឋប្រហារទៅ ឈប់រហូត ។

ថន: ១១ សង្គមចាស់ណ៎លោកពូ?

ធាន: បាទ!

ថន: រដ្ឋប្រហារឆ្នាំ ៧០?

ធាន: បាទ! រដ្ឋប្រហារឆ្នាំ៧៩ ។

ថន: កាលនោះឪពុកម្តាយពូធ្វើអ្វី ធ្វើប្រកបរបរអីដែរ?

ធាន: ធ្វើស្រែចម្ការ ។

ថន: ពូ! ឈប់រៀនអាយុប៉ុន្មាន?

ធាន: ឈប់រៀនខ្ទង់១៥, ១៦ឆ្នាំ ។

ថន: ចឹងពូអាចរៀបរាប់ពីពេលដែលពូឈប់រៀនរហូតមក ពូជួបជាមួយកងទ័ពរំដោះ ពូអាចរៀបរាប់បានទេ?

ធាន: តាំងពីក្រោយពីរដ្ឋប្រហារមក?

ថន: បាទ!

ធាន: ឆ្នាំ ១៩៧៣ ខ្ញុំចូលក្នុងអង្គភាពស្រុក ប៉ុនក្មេងខ្លះអីខ្លះ ជាមួយហ្នឹងគណៈស្រុកឈ្មោះ ថល ។ បានក្រោយឡើងចូលក្នុងអង្គភាពស្រួច ក្នុងកងពល១៦ ។

ថន: គណៈស្រុកហ្នឹងឈ្មោះ ថល?

ធាន: បាទ!

ថន: គណៈស្រុកហ្នឹង ស្រុក?

ធាន: ស្រុក១៦ ស្រុកគៀនស្វាយ ។

ថន: បាទ! ពូ ចូលហ្នឹងគេជ្រើសរើសចូល ឬក៏ស្ម័គ្រចិត្ត?

ធានៈ ជំនាន់ហ្នឹងថាជ្រើសរើសចូលក៏បានដែរ ព្រោះថាអីដើម្បីដូចជាថាសម្ដេចសីហនុគាត់ប្រកាសថា កូនចៅនាំគ្នាចូលព្រៃម៉ាកគីដើម្បីការពារទឹកដីរបស់ខ្លួនឯង ។ មានប្រទេសក្រៅគេមកជ្រៀតជ្រែកចឹងណា ចឹងក៏ចូលបែកចេញពី ឪពុកម្ដាយមក ។

ថនៈ ឪពុកម្ដាយដឹងទេ ពេលដែលពូចូល?

ធានៈ កាលចូលកង់ទ័ពហ្នឹង នៅជាមួយយាយជាមួយតា តែឪពុកម្ដាយអត់ដឹងទេ ។

ថនៈ ចូលនៅឆ្នាំ ប៉ុន្មានលោកពូ នៅចាំឆ្នាំទេ?

ធានៈ ចូលក្នុងឆ្នាំ ៧៣ ។

ថនៈ ខែប៉ុន្មាន?

ធានៈ ថ្ងៃ១ ខែ២ ។

ថនៈ ១៩៧៣?

ធានៈ បាទ!

ថនៈ ចូលហ្នឹង ចូលដំបូងពូធ្វើអីវិញ ហើយនៅឯណា?

ធានៈ ចូលនៅតាមមួយជួរដងទន្លេបាសាក់ក្រោយខាងលិចហ្នឹង ។ មួយជួរស្រុកស្អាង មួយជួរស្រុកកោះធំអីហ្នឹង ។ ដល់ឆ្នាំ៧៤ ជិតដាច់៧៥ ហើយហ្នឹងបានមកនៅមួយជួរគៀនស្វាយ ។

ថនៈ ចូលហ្នឹង ពូធ្វើអ្វីខ្លះពូ?

ធានៈ មួយជំនាន់ហ្នឹង ដើរនៅក្នុងក្រុមកុមារដូចថាជានៅតាមស្នាក់ការ ដូចថានាទីដឹកជញ្ជូនម្ហូបអាហារ ដឹងជញ្ជូនគ្រាប់រំសេវអីហ្នឹងណា ដឹកជញ្ជូនអ្នករបួសនៅតាមទីស្នាក់ការអីហ្នឹងឯង ព្រោះជំនាន់ហ្នឹង ខ្ញុំនៅក្មេងដែរ ព្រោះសែងរបួសអត់រួចដែរ ។ គ្រាន់តែនៅឲ្យមានគ្នាតែប៉ុណ្ណឹងទេ ។

ថនៈ អាយុប៉ុន្មានកាលហ្នឹង?

ធានៈ កាលហ្នឹង អាយុ១៦ ។

ថនៈ នៅស្នាក់ការហ្នឹងយើងប្រចាំការ ឬក៏យើងធ្វើអី?

ធានៈ នៅប្រចាំការ ។

ថនៈ ច្រើនទេពូនេះ?

ធានៈ មួយកន្លែងៗហ្នឹង១៥នាក់ទៅ ២០នាក់ ។

ថនៈ មានបែងចែកជាស្ទីទៀតទេ?

ធានៈ គេបែងចែកពីស្នាក់ការមួយ ទៅស្នាក់ការមួយ ឧទាហរណ៍ថាអ៊ំយើងអ្នកសមរភូមិ គេវាយទៅមានការណ៍គ្រោះថ្នាក់ ដូចថារបួស មួយចំនួនដូចថាពលីកម្មណាចូលមកតាមរយៈស្នាក់ការនេះឯង ហើយស្នាក់ការនេះចេះតែដូរតៗគ្នាទៅ អាកន្លែងតំបន់រំដោះណា ។

ថលៈ លោកពូនៅស្រុក១៦ហ្នឹង ជាមួយ ថល គណៈស្រុក ថល?

ធានៈ បាទ! គណៈស្រុកឈ្មោះ ថល ។

ថនៈ ពូនៅរហូតដល់ឆ្នាំប៉ុន្មាន?

ធានៈ ខ្ញុំនៅហ្នឹងបានប្រហែលជា២ឆ្នាំ ៣ឆ្នាំ ចុងឆ្នាំ ៧៥ ក៏ចូលក្នុងអង្គភាពកងពល១១ ។

ថនៈ ក្នុងឆ្នាំ ៧៥ គេឲ្យជ្រើសរើសចូលតែម្តងហេ៎?

ធានៈ បាទ!

ថនៈ កងពលប៉ុន្មានពូ?

ធានៈ កងពល១១ ។

ថនៈ របស់ភូមិភាគណា?

ធានៈ របស់ភូមិភាគកណ្តាល ។

ថនៈ ភូមិភាគកណ្តាល?

ធានៈ ទេ! មិនមែនភូមិភាគកណ្តាលទីហ្នឹង!

ថនៈ គឺភូមិភាគពិសេស ។ ភូមិភាគពិសេសរបស់នរណាប្រធានភូមិភាគ?

ធានៈ ភូមិភាគជំនាន់ហ្នឹង អត់សូវស្គាល់ដែរខ្ញុំ ។

ថនៈ អត់ស្គាល់ទេ! ចុះប្រធានកងពល?

ធានៈ ប្រធានកងពលឈ្មោះ សោម ប៉ុន្តែត្រកូលអត់ស្គាល់ ដឹងឈ្មោះអីទេ ។

ថនៈ ចុះកងពល១១ហ្នឹង គេមានបែងចែកវរសេនាធំ វរៈអីទៀតទេពូ?

ធានៈ មួយជំនាន់ហ្នឹង មានពីរ វរសេនាធំ៥៤ វរសេនាធំ៥៣ ប៉ុនមេបញ្ជាការវរៈខ្ញុំអត់ចាំដែរ ។ វរសេនាធំហ្នឹងហេ៎?

ថនៈ បាទ!

ធានៈ ចាំតែមេបញ្ជាការវរសេនាតូច ។

ថនៈ ២ហ្នឹង ពូអត់ចាំទាំងពីរ?

ធានៈ បាទ!

ថនៈ ហើយ មានប៉ុន្មានវរសេនាតូច?

ផានៈ វរសេនាតូច៩៣ហ្នឹងមានបីវរសេនាតូច ហើយខ្ញុំនៅវរសេនាតូច៣១ មានលោក ឡាយ សារីម ជាមេបញ្ជាការ ។

ថនៈ វរៈតូច៣១ ។ ឡាយ បូរីម?

ផានៈ ឡាយ សារីម ។

ថនៈ បាទ! ពូនៅក្នុងហ្នឹងតែម្ដង?

ផានៈ ខ្ញុំនៅអាក្នុងអាធំ ។

ថនៈ វរសេនាធំ?

ផានៈ បាទ! ៣២ ។

ថនៈ ៣២ហ្នឹងពីណា?

ផានៈ មេបញ្ជាការ?

ថនៈ បាទ! មេបញ្ជាការ ។

ផានៈ មេបញ្ជាការជំនាន់ហ្នឹងដូចជាភ្លេចដែរ ដូចជាឈ្មោះ លន ។

ថនៈ លន! នៅរស់ទេសព្វថ្ងៃ?

ផានៈ អត់ដឹងដែរ ។

ថនៈ ពូនៅក្នុងហ្នឹងតែម្ដង?

ផានៈ បាទ! រំដោះ៧៥ហើយមកហ្នឹង ឆ្នាំ ៧៦ ចុងឆ្នាំ៧៥ ដើមឆ្នាំ៧៦ មានការរៀបចំកងទ័ព ១៤និង ១១បញ្ចូលគ្នាដាក់៨០១ ។

ថនៈ ក្រោយរំដោះ៧៥ហ៎លោកពូ?

ផានៈ បាទ!

ថនៈ រៀបកងពលលេខ១១?

ផានៈ បាទ!

ថនៈ លេខ១១ហ៎?

ផានៈ បាទ! លេខ១១ និងកងពលលេខ១៤ ។

ថនៈ កងពលលេខ១៤ ទៅជា៨០១?

ផានៈ បាទ! កងពលលេខ១៤ ទៅជា៨០១ ។

ថនៈ កងពលលេខ១១ហ្នឹងមិញហ្នឹង សោម ។ ១៤ហ្នឹងពីណាគេ?

ផានៈ កងពល១៤ ក្រោយពីហ្នឹងទៅមានបង០៥ ហៅតាវឿន ហ្នឹងណា ។

ថន:	តារឿន០៥ ហ្នឹងហ៊េ់?

ផាន:	បាទ!

ថន:	គាត់ឈ្មោះពេញហ្នឹងអីសារឿន?

ផាន:	លោកគ្រូអើយ ពុំសូវដឹងដែរ ។

ថន:	សារឿន០៥ ។ ចឹង២ហ្នឹង បូកបញ្ចូលគ្នាទៅជា៨០១?

ផាន:	បាទ! ១៨ និង១១បូកបញ្ចូលគ្នាទៅជា៨០១ ក៏មួយសារហ្នឹង គេថាអង្គការ ជំនាន់ហ្នឹងបង្កើត ខ្លះប្រើភាសាថាអង្គការហ្នឹងណា អង្គការឲ្យទៅការពារព្រំដែន ព្រំដែនឡាវ ។

ថន:	ព្រំដែនឡាវ?

ផាន:	បាទ!

ថន:	ចុះទៅហ្នឹង ទៅកងពលទាំងមូលតែម្ដងអីលោកពូ?

ផាន:	ទៅ! និយាយរួម៨០១ហ្នឹង ទៅទាំងអស់គ្រាន់តែថាក្នុងកងពលអ៊ំក្នុងវរសេនាធំខ្លះក៏ទៅក្នុងស្រុកនេះខ្លះទៅ វរសេនាធំខ្លះក៏ទៅក្នុងស្រុកនោះទៅ ដល់ចឹងចំណែកយើងវរសេនាធំ អើ ៨២ នៅក្នុងសមាជិក ៨០១ហ្នឹង គេឲ្យឈរជើងនៅស្រុកសៀមប៉ាង ។

ថន:	វរសេនាធំ៨២?

ផាន:	៨២ ។

ថន:	អ៊ូ! ចេញជាកងពល៨០១មួយហើយ គេចាប់ផ្ដើមរៀបវារេជាវរសេនាធំអីឡើងវិញទាំងអស់អីហឹងពូ របនាសម្ព័ន្ធ?

ផាន:	បាទៗ!

ថន:	មានប៉ុន្មានវរសេនាធំ៨០១?

ផាន:	៨០១ហ្នឹង អ៊ំ វាមាន ៨១,៨២,៨៣,៨៤ ។ វាមាន ៤វរសេនាធំ ហើយនឹងមានមួយវរសេនាតូចកងពិសេសហ្នឹងបាទ!

ថន:	៨២,៨៣,៨៤ ក្នុងហ្នឹងមានប៉ុន្មានអនុសេនាតូចទៀត អ៊ូ! អនុសេនាធំ?

ផាន:	នៅក្នុង៨០១ហ្នឹង អ៊ំ មានកងពិសេសរបស់៨០១ ដាក់ឈ្មោះ៨០២ មួយវរសេនាតូចទៀត ។

ថន:	កងពិសេស៨០២!

ផាន:	បាទ!

ថន:	ចឹងអាហ្នឹង នៅចំណុះ៨០១ទេ?

ធានៈ បាទ!

ថនៈ ៨១,៨២,៨៣,៨៤ សុទ្ធតែវរសេនាធំ?

ធានៈ បាទ!

ថនៈ ចុះពូនៅក្នុងកងណាវិញទៅ?

ធានៈ ខ្ញុំនៅក្នុងវរសេនាធំ៨២ ។

ថនៈ បាទ! ចឹងមេបញ្ជាការឈ្មោះអីវិញ?

ធានៈ មេបញ្ជាការឈ្មោះ វ៉ែន ប៉ុនមិនដឹងអី វ៉ែនទេ មួយសារហ្នឹង ប៉ុនឥឡូវគាត់នៅដែរ ។

ថនៈ គាត់នៅណាវិញ?

ធានៈ នៅក្នុង នៅយើងជិតស្វាត នៅអូររុន ។

ថនៈ ចុះប្រធានកងពល៨០១ នរណាវិញ?

ធានៈ ៨០១ ឈ្មោះតារឿន០៥ ។

ថនៈ អូ៎ គាត់នៅកងពល១៨ ដល់ពេលបញ្ចូល១១មក គាត់នៅមេបញ្ជាការដដែរ?

ធានៈ មេបញ្ជាការដដែរបាទៗ!

ថនៈ ហ្នឹង៨០១ ទទួលខាងព្រំដែនលាវ?

ធានៈ ព្រំដែនលាវផង ព្រំដែនវៀតណាមផង ។

ថនៈ ពីណាទៅណា ពូអាចដឹងទីតាំងទេ?

ធានៈ បើតាមនិមិត្តសញ្ញាវរសេនាធំ៨២ ពីដុំក្រឡ ជួរប្រដេងនៅទឹកធ្លាក់ ។

ថនៈ ដុំក្រឡ?

ធានៈ បាទ!

ថនៈ អាហ្នឹងនៅព្រំដែនលាវ?

ធានៈ នៅព្រំដែនលាវ ។

ថនៈ នៅស្រុកអីវិញ?

ធានៈ នៅស្រុកសៀមប៉ាង ។

ថនៈ ដុំក្រឡអីពូ?

ធានៈ ដុំក្រឡ ។

ថនៈ ស្រុកសៀមប៉ាង ។

ធានៈ បាទ!

ថនៈ ស្រុកសៀមប៉ាង! ហើយ៨១ពូ?

ធានៈ ព្រោះអីអន្តភាពផ្សេងមិនដឹងជានៅស្រុកអីខ្ញុំអត់ហ៊ាននិយាយ អត់ហ៊ានថា ។

ថនៈ បាទ! នៅស្រុកស្ទឹងត្រែង ប៉ុន្តែមេបញ្ជាការវរសេនាធំ៨១ នរណាវិញ?

ធានៈ ខ្ញុំភ្លាប់អត់បានដែរ ព្រោះមួយសារហ្នឹងយើងនូវជាយុទ្ធជន ដូជនេះហើយខ្ញុំភ្លាប់អត់បានទេ ។

ថនៈ ចុះកាល៨៣ពូ?

ធានៈ ៨៣ក៏អត់សូវស្គាល់ប៉ុន្មានដែរ ។

ថនៈ ចុះ៨៤?

ធានៈ ៨៤ ពីជំនាន់ហ្នឹងដូចមាន បងកែវចឹង ។

ថនៈ កែវ! ស្អីកែវពូ?

ធានៈ អត់ស្គាល់ដែរ ។

ថនៈ ចុះកងពិសេស?

ធានៈ កងពិសេស៨០២នេះហ៎?

ថនៈ បាទ!

ធានៈ ពីដើមឡើយដូចជាបង ឆន ដែលក្រោយឡើងមេបញ្ជាកាដែលរៀបចំឡើងដាក់នៅ៨០២
ជាកងវរសេនាធំ៨២,៨៣បញ្ចូលគ្នាដាក់៨០២ហ្នឹង ឈ្មោះ ឆន នេះឯង ។

ថនៈ ដល់ចឹងក្រោយមក៨២, ៨៣ បញ្ចូលគ្នាទៀត?

ធានៈ បញ្ចូលគ្នា វរសេនាធំ៥៧ អាហ្នឹងមិនដឹងចជាចេញមកពីប្រភពណា ខ្ញុំភ្លាប់មិនបានក៏ចូលក្នុង
ក្របខ័ណ្ឌ៨០២ហ្នឹងដែរ ។

ថនៈ ចឹងក្រោយមកមានបែងចែកពីរហ្នឹងបូកបញ្ចូលគ្នាទៅជា ៨០២ តែមួយទេ?

ធានៈ បាទ!

ថនៈ ៨២,៨៣,៥៧ មួយទៀត វរសេនាធំ៨២ ។ ចឹង ឆន ហ្នឹងគាត់នៅគ្រប់គ្រងនៅហ្នឹង?

ធានៈ បាទ!

ថនៈ គាត់នៅដាច់ដោយឡែកពីសារឿនហ្នឹង?

ធានៈ បាទ! ដាច់ដោយឡែកហើយ ។

ថនៈ ហ្នឹង នៅឆ្នាំប៉ុន្មានពូ បំបែក?

ធានៈ អ៊ូ! ឆ្នាំ ១៩៨៦ ។

ថនៈ ៧៦?

ធានៈ ៨៦ ។

ថនៈ ពេលដែលបែកហើយ?

ធានៈ បាទ! មកនៅព្រំដែនថៃនេះហើយ ។

ថនៈ គេហៅ១០០១?

ធានៈ មុនគេហៅ១០០១ ប៉ុនឥឡូវគេហៅមុំ៣ ។

ថនៈ មុំ៣, បាទ! កាលហ្នឹងនៅខាងសៀមប៉ាង ខាងអី ខាងកងពល៨០១ នៅក្រោមនេះភូមិភាគឦសាន របស់យ៉ា មែនទេពូ?

ធានៈ ទេ! ដូចក្តាប់ពុំសូវបានដែរខាងលើ ។

ថនៈ ប្រធានភូមិភាគ តាយ៉ាៗ?

ធានៈ មិនដឹងតាយ៉ា មិនដឹងជានរណា ។

ថនៈ តាយ៉ា! បានក្រោយមកគេដូរមានឈ្មោះវី ឈ្មោះអីក្រោយទៀតពូមានចាំទេពូ?

ធានៈ អត់ចាំ!

ថនៈ ចុះពូទៅប្រចាំការនៅហ្នឹង មានរយៈពេលប៉ុន្មានដែរពូ?

ធានៈ មើលពី៧០ចុងឆ្នាំ៧៥ ដើមឆ្នាំ៧៦ រហូតមកដល់ឆ្នាំ៨១ បានយើងនៅមុំ៣ ។ ១០០១ ណា! បានរយៈ៥ឆ្នាំ ដែលទាហានវៀតណាមវាយនៅតាមជួរព្រំដែននៅលើមុំ៣ហ្នឹង ក៏បែកបាក់មូលដ្ឋានទៅ ក៏យើងមកនៅឯម្តុំដងទង់ចងកទឹកដីថ្ងៃណា ។

ថនៈ ពូមកដល់ម្តុំក្រឡដំបូងនៅឆ្នាំប៉ុន្មាន?

ធានៈ ៧៦ ។

ថនៈ ៧៦?

ធានៈ បាទ!

ថនៈ ខែប៉ុន្មាន?

ធានៈ មួយសារទៅហ្នឹង ខែ១ ។

ថនៈ ទៅដល់ហ្នឹង ពូបោះទីតាំងនៅម្តុំក្រឡហ្នឹងតែម្តង?

ធានៈ អត់ទេ! បោះទីតាំងនៅស្រុកសៀមប៉ាង ។

ថនៈ ទៅហ្នឹង ទៅទាំងអស់តែម្តង ឬក៏ទៅយ៉ាងម៉េចដែរ?

ធានៈ អត់ទេ! ដកតាមអនុសេនាធំ ។ តាមវរសេនាតូចដក់យកតាមអនុសេនាធំហ្នឹងដើម្បីយកទៅចាំតាមចំណុចៗ ទៅនឹងការប្រាស្រ័យទាក់ទង ។

ថនៈ ហើយនៅនោះសភាពការណ៍យ៉ាងម៉េចដែរ អាចរៀបរាប់បានទេ?

ធានៈ ពីជំនាន់នោះអត់អីទេ ព្រោះលាវក៏គេរព្ធភាពដែនដីរបស់ខ្មែរ អត់ហ៊ានលុកដៃ លុកជើងអីទេ ។

ថនៈ ចុះពូមានឮថា មានមន្ទីរសន្តិសុខនៅបឹងកន្សែង?

ធានៈ អាហ្នឹងបឹងកន្សែង ខ្ញុំមិនយល់ដែរ រឿងពីសន្តិសុខ បញ្ហាអីហ្នឹង ព្រោះអីខ្ញុំមិននៅខេត្តស្ទឹងត្រែងទេ នៅក្នុងខេត្តរតនៈគិរី ។

ថនៈ នៅស្រុកអីវិញពូ?

ធានៈ មិនដឹងស្រុកអីទេ! មិនដឹងថានៅស្រុកវឺនសៃ ឬក៏បានលុង ខ្ញុំក៏ភ្លាប់មិនបានដែរ ។

ថនៈ តែថាអ្នកដែលមានកំហុសអីត្រូវគេបញ្ជូនទៅហ្នឹងដែរ ស្ទឹងត្រែង សៀមប៉ាងណា?

ធានៈ បាទ! ភាគច្រើនគេបញ្ជូនទៅក្នុងខ្ទីដែរ យើងភ្លាប់ពុំសូវបាន គិតតែប្រឹងរឿងការងារដើម្បីរក្សាសុកខ្លួនឯង ព្រោះជំនាន់យើងហ្នឹង ថាវាតឹងតែងដែរ សូម្បីថារើសខទាហរណ៍ថាស្រូវអង្ករអីដែលយើងធ្វើផលិតបានហើយហ្នឹង ក៏ហូបមិនបានពេញលេញដែរ ។ ដល់ចឹងទៅថាការងារអីគេប្រគល់ឲ្យ គិតតូការងារនោះទៅ ខទាហរណ៍ថាគេឲ្យមើលគោ ក្របី គិតតែមើលគោក្របី កុំឲ្យតែបាត់បង់ ប៉ុណ្ណឹងវាល្អហើយ ។

ថនៈ នៅនោះពូនៅតែមួយកន្លែង ឬពូចល័តទៅណាទៀត នៅស្រុកសៀមប៉ាង?

ធានៈ ខ្ញុំនៅស្រុកសៀមប៉ាងមួយសារនោះគេឲ្យដើរតាមមូលដ្ឋានភូមិខិ, ភូមិស្វាយ, ភូមិសំយោគហ្នឹងនៅជាមូលដ្ឋាន ប៉ុនគ្រាន់តែនៅហ្នឹង ក៏នៅក្នុងលក្ខណៈបង្កបង្កើតផលដែរ ។

ថនៈ ប៉ុន្មានភូមិហ្នឹង សុទ្ធតែនៅទីតាំងស្រុកសៀមប៉ាង?

ធានៈ បាទ!

ថនៈ ចុះនៅនោះ អត់មានប៉ះទង្គិចខាងនេះ?

ធានៈ អត់មានទេ! ព្រោះអីអត់មានក្បែរព្រំដែនវៀតណាមផង ។

ថនៈ វានៅឆ្ងាយ ។

ធានៈ បាទ! វានៅព្រំដែនលាវ ប៉ុន្តែលាវអត់មានអីទេ ។ លាវមួយជំនាន់នោះគេគោរពដែនដីគេត្រឹមត្រូវ យើងគោរពដែនដីរបស់យើងត្រឹមត្រូវ ជំនាន់ហ្នឹងណា ។

ថនៈ មួយវរសេនាធំរបស់ពូ មានប៉ុន្មាននាក់?

ធានៈ វរសេនាធំ អាមួយជំនាន់ដែលចេញចំ៨០១ហ្នឹង ហ៊ាកអពល១១ និង១៤ ចូលគ្នាចឹងទៅ ១អនុសេនាតូចវាស្មើរហ្នឹង៣៦នាក់ ។ ដល់ចឹងវាវរសេនាធំ វាមានអ៉៣វរសេនាតូច សរុបទៅវាច្រើនដែរ ។ ចូលដល់ពាន់ដែលហ្នឹង ។ ដល់ចឹងពីអង្គភាពមួយទៅអង្គភាពមួយស្គាល់គ្នាពុំអស់

ទេ បាទ! ព្រោះរៀបចំបញ្ចូលគ្នាថ្មីថ្មោងផងៗ ម្យ៉ាងទៀតតាមវរៈនីមួយៗយើងក៏មិនមានលទ្ធភាពអីទំនាក់ទំនងដែរៗ គ្មានការផ្សារអត់បានទៅទំនាក់ទំនងទេៗ ដល់ចឹងក្ដាប់ចំនួនបញ្ហាទៅតាមអង្គភាពមួយៗ ចំនួនប៉ុន្មានៗក្ដាប់ពុំបានទេៗ

ជនៈ ចុះពូនៅបន្តបង្កើតផល ឬក៏មានដកពូទៅអង្គភាពផ្សេង ពេលវាយគ្នាទៅតាមព្រំដែន?

ធានៈ ខ្ញុំ មួយជំនាន់ហ្នឹងរង្គោះរង្គើគ្នានៅតាមព្រំដែនវៀតណាមខ្មែរហ្នឹង ខ្ញុំនៅឈរស្រុកសៀមប៉ាងហ្នឹងដែរ ប៉ុន្តែដល់ពេលវាយដាច់នៅតាមជាយដែនមកដល់វឺនសៃហ្នឹង អង្គភាពក៏ឲ្យខ្ញុំទៅជួយធ្វើអន្តរាគមន៍គេនៅស្រុកវឺនសៃ ប៉ុនក្នុងរតនៈគិរីហ្នឹងណាៗ

ជនៈ ពេលសភាពការប្រទូស្តប្រទះគ្នាណ៎ពូ?

ធានៈ បាទ!

ជនៈ កាលហ្នឹងវៀតណាមចូលដល់?

ធានៈ ចូលដល់វឺនសៃៗ

ជនៈ ចូលដល់វឺនសៃៗ

ធានៈ បាទ!

ជនៈ ទៅតែមួយវរៈរបស់ពូ ឬក៏ទៅទាំងអស់តែម្ដង?

ធានៈ និយាយរួម កម្លាំងមួយចំនួនទៅព្រំដែនតាំងពី៧៨ណ៎ ទាំងពីតឹងតែង ទៅមួយភូមិគងភូមិក្រឡែ ប៉ុនខ្ញុំឮសូរតែពាក្យតាមគេនិយាយនោះទេប៉ុនខ្លួនឯងអត់ដែលបានទៅទេ ព្រោះអីខ្លួននៅឈរស្រុកសៀមប៉ាងហ្នឹងរហូតប៉ុនដល់ពេលវាយទៅពីមុខមកបាក់មក ក៏មកទើគ្នានៅត្រឹមវឺនសៃហ្នឹង ក៏គេរៀបរយកម្លាំងពួកខ្ញុំនៅស្រុកសៀមប៉ាង ក៏ទៅជួគេៗ ទៅជួយរយៈបានប្រហែលជា ១ ខែ ២ខែ សភាពការវាទៅពុំរួចក៏នាំគ្នាដោះស្រាយជញ្ជូនស្បៀងៗ

ជនៈ ទៅមិនរួចយ៉ាងម៉េចពូ?

ធានៈ ទៅមិនរួចដូចថា វៀតណាមពេញទូទាំងប្រទេស ដល់ចឹងមានតែនាំជញ្ជូនស្រូវជញ្ជូនអង្ករជញ្ជូនអំបិល ជញ្ជូនប្រហុកអីចូលព្រៃទៅ ដូចជាថ្នាំសន្លូវអីនៅតាមសហករណ៍សេសសល់ហ្នឹង ក៏ជញ្ជូនលាក់ទុកក្នុងព្រៃទៅ បាទ!

ជនៈ នៅព្រៃហ្នឹងនៅហ៎ នៅស្រុកវឺនសៃហ្នឹង ឬក៏?

ធានៈ នៅស្រុកសៀមប៉ាងៗ

ជនៈ នៅសៀមប៉ាង?

ធានៈ បាទ!

ថនៈ	កាលហ្នឹងអ្នកបញ្ជាវាយជាមួយវៀតណាមផ្ទាល់មកនៅរីនសៃ?

ធានៈ	នៅរីនសៃ មានតែ០៥ហ្នឹងហើយ ។ មួយសារហ្នឹងវាដាច់ដោចអស់ហើយ លើក្រោមទាក់ទងគ្នាពុំបានទេ ។

ថនៈ	វាយហ្នឹងនៅឆ្នាំប៉ុន្មានពូ?

ធានៈ	នៅឆ្នាំ៧៩ ។

ថនៈ	ពូនៅរីនសៃ?

ធានៈ	បាទ!

ថនៈ	ចុះបន្ទាប់ពីហ្នឹងហើយមានទៅណាទៀត ឬក៏ឈរជើងនៅតែមុំហ្នឹងទេ?

ធានៈ	នៅតែមួយជួរស្រុកសៀមប៉ាង ប៉ុនថាយើងពុំបានទៅក្នុងទីរួមស្រុកនោះទេ ព្រោះអីដូចថាវៀតណាមគេយកអស់ហើយ ដូចនេះមានតែជញ្ជូនស្បៀងចូលទៅក្នុងព្រៃ ។ ដល់ឆ្នាំ១៩៨១ហ្នឹងបានអន្តភាពខ្ញុំត្រូវតែឆ្លងមកលិច ព្រោះខាងលិចគេមានការរៀបរយជាមូលដ្ឋានមានហើយ ប៉ុននៅក្នុងព្រំដែនថៃ ដែលជាប់ព្រំដែនថៃដែលថា១០០១ហ្នឹង ។ កាលហ្នឹងបានមេបញ្ជាការអន្តភាពហ្នឹង ក៏រៀបរយឲ្យមកនៅ យើង១០០១ហ្នឹង ។

ថនៈ	ថាឈ្មោះរ៉ែនហ្នឹង?

ធានៈ	បាទ! ឈ្មោះរ៉ែនហ្នឹង ។

ថនៈ	ឈ្មោះ រ៉ែន ឬក៏ឈ្មោះ ឆន?

ធានៈ	ឈ្មោះ ឆន ហ្នឹង អាហ្នឹងអ៎!

ថនៈ	ក្រោយ៨៦ទេ?

ធានៈ	បាទៗ! អាហ្នឹងក្នុងឆ្នាំ៨៦ ។

ថនៈ	ចុះពូកាលហ្នឹងអត់ទាន់ឆ្លងទន្លេមកខាងនេះដែរ?

ធានៈ	នៅ! ទាល់ដល់ឆ្នាំ៨១៦នោះទើបបានឆ្លង ។ ដល់ឆ្លងទៅឆ្លងមោដីលាវ ខេត្តចម្ប៉ាសាក់ឆ្លងប៉ុន្មានប្រហែលជា១៥០០នាក់ ប៉ុនបានជាក់ស្តែងមកដល់នេះបានតែ៧០០នាក់ទេ ។ វាត្រូវលង់ទឹកខ្លះ ត្រូវលាវហ្នឹងបាញ់ស្លាប់ ខ្លះកម្លាំងមួយចំនួនក៏ត្រលប់ថយក្រោយវិញអត់ចេះហែលទឹក ។

ថនៈ	ទៅជាង១០០០០នាក់ហ៎ពូ?

ធានៈ	បាទ! បើត្រូវឆ្លងត្រូវ១៥០០នាក់ ។

ថនៈ	ចុះម៉េចបានទៅយើងឆ្លងចូលលាវហើយ ហើយអត់ឆ្លងកាត់ទន្លេមេគង្គមក?

ធានៈ ឆ្លងចូលលាវ ក៏ហែលទឹកទន្លេមេគង្គដូចគ្នា ។

ថនៈ ហែលពីលើជួរប្រដេងហ្នឹង ខ្លះហ្នឹងក៏វាក៏ក្បែរជួរគេ ទៅជួនកាលក៏ធ្លាក់មួយជួរក៏ស្លាប់ទៅណា ព្រោះជួរប្រដេងទឹកធ្លាក់ជ្រៅណាស់ ។

ធានៈ ជួរប្រដេងពូ?

ថនៈ បាទ! ជួរប្រដេង នៅខេត្តចម្ប៉ាសាក់អី?

ធានៈ អត់ទេ! អាហ្នឹងយាយទៅវាជាប់ព្រំប្រទល់ព្រះវិហារ និងស្ទឹងត្រែង ។ បើលាវថាចម្ប៉ាសាក់ហ្នឹងហើយ ។

ថនៈ បាទ! អាហ្នឹងនៅក្នុងដីខ្មែរទេពូ?

ធានៈ ជួរប្រដេងនៅជាប់ព្រំដែន ។

ថនៈ ខាងលាវមានបាញ់ មានអីដែរ?

ធានៈ បាទ! ដល់ពេលយើងឆ្លងចឹងមកព្រំដែន គេការពារទឹកដីគេហើយ ។ ស្ពឹកដៃស្ពឹកជើង នៅក្នុងខែ១ វាត្រជាក់ ដល់ចឹងទៅស្ពឹក ដល់ស្ពឹកជួនកាលទៅ ក៏ហែលអត់ឆ្លងផុត អាជួរហ្នឹងក៏ទឹកហូរស្រូបចូលជួរហ្នឹងក៏ស្លាប់ទៅ អ្នកខ្លះក៏របូតដៃរបូតក្បូនអីចឹងទៅណាស់ ។ មួយពួកខ្ញុំមួយជំនាន់ហ្នឹងវេទនាណាស់ទម្រាំបានសុខសាន្តប៉ុណ្ណេះ ។

ថនៈ ពូគិតថាមិនសមរស់បានមកដល់សព្វថ្ងៃ?

ធានៈ បាទ! មិនសមថារស់ទេ ដល់ពេលយើងរំឭកពីប្រវត្តិដើមដែលយើងមានការលំបាក ដល់សព្វថ្ងៃនេះ មិនសមហ្នឹងថាបានរស់ទេ បើនិយាយរឿងថាហូបចុកវិញពី៧៩មកដល់ឆ្នាំ៨១ ហូបនិយាយរួមថាអត់មានអំបិលភាគច្រើនយើងហូបតែខទាហរណ៍ថា មើមខ្ទុយដូចថារបស់ដែលមានជាតិថាហឹរតិចៗ ហើយជួនកាលយើងហូបជាមួយក្តួច ជួនកាលក្តួចយើងស្ងោរពេលហ្នឹងពេលយើងធ្វើដំណើរមានស្ពឺ មានស្បៀងតាមទេ ដល់ចឹងគាស់អាក្តួចយកស្ងោរ ពេលដែលយើងធ្វើដំណើរអត់មានស្បៀងតាមទេ ដល់អីចឹងគាស់អាក្តួចយកមកស្ងោរៗ ហើយអង្គុយជ្រាវចឹងទៅ ។ សាបមិនសាបអីជួនកាលហូបទៅក្រពុលៗក៏ដេក ដេកទៅល្ងាចឡើងក៏ធ្វើដំណើរទៅទៀតទៅ វេទនាណាស់ជំនាន់ហ្នឹង ទៅរកក្តួច ក្តួចទទេទៅ ជួនកាលទៅមានដើមយើងទាលធំៗ ស្រុកហ្នឹងគេសម្បូរណ៍ណាស់ដើមទាល ខ្លះប៉ុនចុងភ្លៅហឹងណ៎ ។

ថនៈ ដើមទាល ដើមយ៉ាងម៉េចទៅ?

ធានៈ ដើមទាលដូចដើម ក្រឡៀង ប៉ុនដូចថាដើមក្រឡៀងហ្នឹង វាតូចៗ ដើមទាលហ្នឹង ប៉ុនៗចុងភ្លៅ ។

ថនៈ ដូចដើមដូង ឬដើមត្នោត ឬក៏ដើមយ៉ាងម៉េច?

ធានៈ អត់ទេ! ដើមសាច់វាសាច់វាស្ដោតៗ ដូចយើងដើមគ្រគៀតៗចឹងទៅណា ៗ ដើមវាកំពស់ ១ម៉ែត្រកន្លះ ប៉ុនៗចុងភ្លៅលីអាហ្នឹងតាមដើរទៅអាហ្នឹងឃើញគាត់ដើរលីតាមទៅពេលសម្រាក សម្រាកទៅក៏ចិតដាក់ឆ្នាំងស្ងោរទៅ រលួយអស់ទៅក៏នាំគ្នាហូបទៅ បាត់អាជាតិរមាស់ ក៏នាំគ្នាហូប ដល់ពេលវេលាធ្វើដំណើរក៏ធ្វើដំណើរទៅទៀតទៅ ។

ថនៈ កាលហ្នឹងពីណាដឹកនាំដែលទៅ?

ធានៈ ជំនាន់ហ្នឹងមានអ៊ំ បង វ៉ែនហ្នឹង៦៨ ៗ គាត់ជាមេបញ្ជាការពិតមែនតែគាត់មិននេះ គាត់មិនបានជាប់ជាមួយគាត់ ឆ្លងមកមុនផុតក៏គាត់មានការអប់រំគាត់មានការណែនាំតាមកម្លាំងតាមមួយរយៈហ្នឹងណា ៗ

ថនៈ ហើយ១០០១ហ្នឹង មានអ្នកទៅដល់អ្នករៀបចំហើយ ឬនៅ? មានអ្នកទៅដល់មុនហើយឬនៅ?

ធានៈ មានគេមកដល់មុន ខ្លះគេមកដល់តាំងពីឆ្នាំ ៨០៦នោះ មានមូលដ្ឋាន មានអ៊ីខៀវ គេថាសុន សេន ហ្នឹងណា៎ ៗ បាទ! គាត់មកឈរជើងនៅហ្នឹងមុនៗ ហើយមានបងរឿន០៥ហ្នឹង គាត់បានមកដល់ហ្នឹងមុន ៗ

ថនៈ ដំណាលសុន សេន ឬក៏មកក្រោយគ្នាពូ?

ធានៈ អាចគាត់មកមុន តារឿន០៥ហ្នឹង តាមដឹងណា ៗ

ថនៈ ពេលពូមក ៨១ហ្នឹង អាហ្នឹងវៀតណាមវាយខ្លាំងតែម្ដង ឬក៏យ៉ាងម៉េច?

ធានៈ ឆ្នាំ ៨១ និយាយរួមទៅអ៊ំ វៀតណាមវាទូទាំងប្រទេសកម្ពុជាវានៅពេញអស់ហើយ យើងដើរគេចដើរវាង ដឹងតែចំណុចណាមានភូមិ មានវៀតណាមនៅ ចឹងយើងអត់ដើរក្បែរទេ យើងដើរវាងឲ្យឆ្ងាយពីភូមិចឹងទៅ ហើយជំនាន់ហ្នឹង យើងមានអាវុធគ្មានគ្រាប់ ដើម្បីតស៊ូនឹងគេទេ ជួនកាលដកទ័ពត្រង់កន្លែងចំណុចណាមានការផ្លូវឆ្លងកាត់ចឹងយើងវាយគ្នា យើងមិនឲ្យមានដានទេ ដើម្បីរក្សាដានហ្នឹង ព្រោះអីបើគេឃើញដានគេតាមយើងច្បាស់ជាគេកំទេចយើងហើយ ដល់ចឹងមានតែវាយ បំបែកដាន កុំឲ្យមានឃើញដានឲ្យឆ្ងាយពីផ្លូវមក បានដើរចូលរួមផ្លូវតែមួយវិញ ៗ

ថនៈ ចុះពូមកហ្នឹង មកទាំងអស់គ្នា ឬក៏នៅខ្លះនៅសៀមប៉ាង?

ធានៈ ជំនាន់ខ្ញុំមកហ្នឹងត្រូវមកទាំងអស់ ប៉ុនដាក់ស្ដែង មកដល់ដងទន្លេហ្នឹងអ្នកខ្លះក៏មិនចេះហែលទៅក៏បកក្រោយវិញទាំងយប់ទាំងអាធាត្រចឹងទៅណា៎ស ព្រោះអីយើងនៅក្នុងអត់បានទេ ៗ ដល់ចឹង

ទៅ ក៏ត្រលប់មកក្រោយវិញ អ្នកថាមកដល់ទន្លេហើយក៏ ទោះបីថាលំបាកក៏ត្រូវតែខំរុលមកមុខ ដើម្បីមានបាយហូប ក៏នាំគ្នាហែលឆ្លងទឹក មកអ្នកខ្លះហ្នឹងក៏ស្ពឹកដៃស្ពឹកជើងចឹងទៅ របូតពីក្បូនចឹងទៅអ្នកខ្លះក៏ ហែលមកធ្លាក់ទៅជួរប្រជេង ក៏ស្លាប់ទៅ ។

ថន: ឆ្ងាយទេពូដល់ហែលឆ្លង ប្រវែង?

ធាន: ហែលឆ្លងយើងបានស្គាល់ទាំងអស់គ្នា ជងទន្លេមេគង្គវាធំដែរ ហែលទម្រាំផុតវាគួសមដែរ ។

ថន: ប៉ុន្មានម៉ែត្រ?

ធាន: ជិតប្រហែលជាជាប់១គីឡូជិ តាមទន្លេហ្នឹងណា៎ ។ ហើយក្នុងរយៈពេលហែលហ្នឹង ៨០ ផ្លោងរហូត តែផ្លោងហ្នឹងផ្លោងដាក់តែខាងក្រោយទេ អត់មាផោងដាក់ទន្លេទេ ។

ថន: ម៉េចបានគេអតតផ្លោងដាក់?

ធាន: តាមមើលវាក្លាប់មិនបាន ដែលថាយើងហែលទឹកដែរ ព្រោះយើងផ្លោងដាក់ថ្ងៃទី១ហ្នឹងខាងអង្គភាព៨០ ១ហ្នឹង គេត្រូវតែវាយទីតាំងណាមួយដើម្បីរំដោះទីតាំងហ្នឹងយកទុក យកកាណូតដើម្បីចម្លងអ្នកមកពីកើតហ្នឹង ។ ទទួលយប់ទីមួយហ្នឹងអត់មកដល់ទេ ដល់ចឹងបែកការដល់បែកការចឹងទៅ ធម្មតាយើងនៅទីតាំងយើងការពារទីតាំងយប់ឡើងផ្លោងដាក់ទៅក្រោយកើត ប៉ុនផ្លោងទៅផុតៗពីកម្លាំងពួកខ្ញុំធ្វើដំណើរហ្នឹង ។ មកដល់មាត់ទន្លេក៏ភ្លៃព្រុសឲ្យទ្រហឹងប្រជាជននោះផ្អើរឆោឡោពេញភូមិទៅណា ដល់ចឹងយើងក៏រៀបរយចងក្បូនក៏ហែលមក ។ មកដល់ក្រោយលិចក៏ប្រជាជនមួយចំនួនគាត់មាននិស្ស័យជាមួយ ជាតិខ្មែរយើងដែរ ហើយខ្លះគាត់ដាំបាយដំណើប អើធម្មតា តែធ្វើសង្គ្រាមតែងមានបណ្តាញទាក់ទងហ្នឹងណា៎ ដល់ចឹងទៅគេរៀបចំដាំបាយដាំទឹកទទួលអ្នកកម្លាំងមកពីកើត ។

ថន: ហ្នឹងជាខ្មែរដែរ ឬខ្មែរតាមមូលដ្ឋាន តាមភូមិតាមអីហ្នឹងហេ៎?

ធាន: បាទ! ប៉ុនមិនខ្មែរយើងទេនៅក្នុងខេត្តចម្ប៉ាសាក់ ប៉ុនភាគច្រើនខ្មែរយើងដែរ ។ តាមខ្ញុំសួរនាំទៅអ្នកព្រៃវេង ស្វាយរៀង តាកែវ នៅតាមជងទន្លេក្រោយខាងលិច នៅតាមចម្ប៉ាសាក់ជិលាវហ្នឹងណា ។

ថន: ខាងជិលាវទេ?

ធាន: បាទ! ដល់សួរគាត់ទៅស្រុកកំណើតគាត់ពីដើមនៅតាកែវ នៅស្វាយរៀង សុទ្ធតែខ្មែរយើងដាច់ដោចច្រើន ។

ថន: គាត់ទៅរស់នៅហ្នឹងតែម្តង?

ធានៈ    បាទ! ប៉ុន្តែគាត់ទៅហ្នឹងតាំងពីជំនាន់ណា ក៏ពុំបានសួរគាត់ឲ្យល្អិតល្អន់ដែរ ព្រោះអីយើងម្យ៉ាង វាស្ពឹកដៃ ស្ពឹកជើងវារងាររជង អាំងភ្លើងគាត់ដុតភ្លើង ហើយក៏សួរនាំពីសុខពីទុក្ខ ពីប្រជាជនហ្នឹងទៅណ៎! ដល់ចឹងយល់ពីការស់នៅរបស់គាត់ យល់ពីស្រុកភូមិរបស់គាត់ខ្លះ ។

ថនៈ    គាត់និយាយភាសាខ្មែរ?

ធានៈ    គាត់និយាយភាសាខ្មែរយើង ។

ថនៈ    ខេត្តចម្ប៉ាសាក់! ប៉ុនពូនៅចាំទីតាំងនៅក្នុងឃុំអី?

ធានៈ    អត់ចាំដែរ នៅក្នុងភូមិអីតាមដងទន្លេមេគង្គ ។

ថនៈ    ព្រោះខេត្តនៅចម្ប៉ាសាក់ វាធំណាពូ!

ធានៈ    ប៉ុនមិនដឹងថានៅក្នុងភូមិអី នោខាងក្នុងអី បានធ្វើដំណើរពីហ្នឹងទៅទៀតចូលមកជួរភូមិព្រាលឃុំក្លីង មកជាយដែនជិតមុំ៣នេះដែរហ្នឹងណា បាទ! អាហ្នឹងបានស្គាល់ភូមិខ្លះ ។

ថនៈ    ភូមិព្រាលហ្នឹងនៅក្នុងទឹកដីខ្មែរទេ?

ធានៈ    ទេ! ភូមិព្រាលហ្នឹងនៅទឹកដីលាវតា ឆ្លងកាត់តាមដីលាវទាំងអស់ ។

ថនៈ    តាមដីលាវ ចូលដីលាវ?

ធានៈ    បាទ!

ថនៈ    ចុះពូថាមានទាហានលាវបាញ់ស្លាប់ យើងដើរទៅអត់មានប៉ះ ប៉ះអ្នកផ្សេងយ៉ាងម៉េច?

ធានៈ    ប៉ះអ្នកផ្សេងទេ ថាមានអ្នកឈឺឡើងពីទន្លេមក អ្នកឈឺ ឬមានអ្នកស្ពឹកដៃស្ពឹកជើងឡើងមិនទាន់រួចហ្នឹង រដ្ឋាភិបាលលាវក៏ចាប់ខ្លះទៅ ហើយខ្លះក៏រត់រួចហ្នឹងក៏រដ្ឋាភិបាលលាវក៏បាញ់ត្រូវ ក៏ស្លាប់ទៅ ហើយគេចាប់មួយចំនួនគេបញ្ជូនទៅវៀងច័ន្ទទៅ ដល់ទំនាក់ទំនងរដ្ឋាភិបាលខ្មែរចឹងទៅក៏គេបញ្ជូនមករដ្ឋាភិបាលខ្មែរវិញ អាហ្នឹងមួយចំនួន ។

ថនៈ    ចាប់ទៅច្រើនទេ?

ធានៈ    ទេ! មួយជំនាន់ហ្នឹង ខ្ញុំក្តាប់មិនបានចំនួនប៉ុន្មានៗដែរ តែគ្រាន់តែដឹងថាមានចាប់បានខ្លះ ។

ថនៈ    ពូ រយៈពេលប៉ុន្មានថ្ងៃបានពូទៅដល់នេះ?

ធានៈ    ទៅដល់ជជុំរុំមុំ៣នេះវិញហ៎?

ថនៈ    បាទ!

ធានៈ    មើលខ្ញុំដើរប្រហែលជា៣ថ្ងៃ  ៣ថ្ងៃបានមកដល់យើងមុំ៣ អាហ្នឹង១០០១ហ្នឹងណា ។

ថនៈ    ពីសៀមប៉ាំងមក ពូ?

ធានៈ    អត់ទេ! ពីសៀមប៉ាំងមកយូរថ្ងៃណាស់ រាប់ខែតែម្តង ។

ជនៈ	រយៈពេលប៉ុន្មានពីសៀមប៉ាងមកដល់ឆ្នងទន្លេ?

ធានៈ	មកដល់ឆ្នងទន្លេប្រហែលជាកន្លះខែណ៎ ។ ប៉ុនថាយើងមកមិនថា ហ៎ទិសដៅមកៗរហូតនោះទេ ជួនកាលមកចឹងទៅ កន្លែងណាមានក្តួចមានដំឡូងក៏ស្នាក់នៅហ្នឹងទៅ មើលសភាពការណ៍ដែរណា មើលសភាពការណ៍ដែលឆ្ងាយពីភូមិ មិនមានប្រជាជនណាជួល់ ហើយកន្លែងណាដែលមានក្តួច មានដំឡូងក៏សម្រាកនៅទីនេះទៅ ៣,៤,៥ថ្ងៃ ក៏ធ្វើដំណើរមកទៀត ។ ថាវេទនាណាស់អូន អើយ ដូចថាមិនសមរស់បានប៉ុណ្ណឹងទេ ។

ជនៈ	នៅស្រុក ខាងលាវនោះបានយូរទេពូ?

ធានៈ	ស្នាក់នៅលាវយើងអត់មានស្នាក់បានទេ ព្រោះអីយើងឆ្លងកាត់ដីគេចឹងទាហានលាវដែលវាមាន ការទំនាក់ទំនងជាមួយខ្មែរអើថាទាហានខ្មែរក្រហមហ្នឹងណា ដល់ចឹងទៅក៏វាជួនផ្លូវឆ្លងកាត់តាមដី លាវ ។ ដល់ចឹងអត់មានកន្លែងស្នាក់នៅបានទេ ចូលដីលាវចាប់ផ្តើមទាំងយប់ ទាំងថ្ងៃតែម្តង ។ សូម្បីតែអ្នកឈឺល្មមៗ ដែលអាចសែងបានក៏សែង បើសែងមិនបានក៏មានការចោលខ្លះ ជីវិតខ្មែរយើង  អត់មានពេលស្រួលទេ ។ គ្រាន់តែខ្ញុំដឹងក្តីមកមិនដឹងប៉ុន្មានសង្រ្គាមមក ហើយ ។

ជនៈ	ចុះអ៎ពូទៅដល់១០០១ មានការរៀបចំយ៉ាងម៉េចដែរ? ពូអាចរៀបរាប់ ហូបចុកអី?

ធានៈ	មកដល់ ១០០១ ដូចថាយើងក្នុងជំរំកែហ្នឹង ពីការហូបចុកអីអត់ចេះខ្វះទេ ដូចថាការដឹកនាំយក ចិត្តទុកដាក់ ឃ្លានថ្នាលណាហូបថ្នាលហ្នឹង អត់មានការខ្វះខាតអីទេ តាំងពីម្ហូបម្ហារឡើងទៅ រួចបរបូរណ៍ តាំងពីសម្លៀកបំពាក់ គឺងពីចុងជើងរហូតដល់ក្បាល អត់មានខ្វះទេ ។

ជនៈ	ខាងណាឧបត្ថម?

ធានៈ	ជំនាន់ហ្នឹងដូចជារបស់របបអាចចេញមកពីចិន ។

ជនៈ	ចេញមកចិន?

ធានៈ	បាទ! តាំងពីអាវុធ តាំងពីគ្រាប់ តាំងពីសម្លៀកបំពាក់ ឧបករណ៍ប្រើប្រាស់ទាំងអស់ ។

ជនៈ	ចុះពូទៅដល់នោះគេរៀបចំម៉េចវិញ?

ធានៈ	បាទ?

ជនៈ	ខាងកងពូ ហើយពូផ្ទាល់គេរៀបចំឡើងវិញយ៉ាងម៉េចវិញ?

ធានៈ	រៀបចំដូចយើងអង្គភាពពីដើមមកវិញដែលថា ឧទាហរណ៍ថាពីដើមយើងអង្គភាពណាក៏នៅតាម អង្គភាពនោះដដែល ដូចជំនាន់យើងមុនសង្រ្គាមចឹងណា ។ ដល់ពេលក្រោយឡើង ឥឡូវទៅ

អង្គភាពនេះខ្វះខាតរឿងស្នូលដឹកនាំចឹងទៅ គេសុំស្នូលដឹកនាំម្នាក់ ២នាក់ដើម្បីជួយពង្រឹងអង្គភាព ផ្សេងអីចឹងទៅណា ។

ជនៈ ចុះពូនៅអង្គភាពវរសេនាធំ៨២នេះ ពូនៅដដែរ?

ធានៈ បាទ! កងពល៨០១ ។

ជនៈ កងពល៨០១ រ៉េនគាត់ដឹកនាំហ្នឹង?

ធានៈ បាទ! បងរ៉េនហ្នឹងគាត់ មួយជំនាន់ហ្នឹងគាត់វរសេនាធំ ដល់ក្រោយឡើងគាត់ឡើងកងពលដែរ ។

ជនៈ គាត់ឡើងកងពលហ្នឹងក្រោយពេលវរសេនាធំ៨២,៨៣ ហើយ ៥៧បូកបញ្ចូលគ្នា?

ធានៈ ទេ! អាហ្នឹងគាត់ឡើងតាំងពីមុនហ្នឹងទៀត ។

ជនៈ គាត់កងពលលេខប៉ុន្មានគាត់ឡើង?

ធានៈ គាត់ឡើងក្នុងកងពល៨០១ហ្នឹង ដែរ ។

ជនៈ រ៉េន ប្រធានកងពល៨០១?

ធានៈ អត់មែនទេ! ប្រធានបង០៥ដដែរ ។

ជនៈ ប៉ុន្តែគាត់ប្រធានកងពលលេខប៉ុន្មានពូ?

ធានៈ ពីណា?

ជនៈ រ៉េន ។

ធានៈ បងរ៉េន ហ្នឹង គាត់ឡើងហ្នឹង គាត់នៅក្នុងក្របខ័ណ្ឌ៨០១ដែរ ប៉ុន្តែគាត់គ្រាន់តែថាជាសមាជិកទីប៉ុន្មានៗ ឬក៏បញ្ជាការអីចឹងណា ។

ជនៈ ប៉ុននៅក្នុងក្របខ័ណ្ឌ៨០១នេះ?

ធានៈ បាទ! ក្នុងអ៊ីរឿននេះគាត់ដែរ ។

ជនៈ ចុះ ពេលរហូតដល់ឆ្នាំ៨៦នេះពូហ៎?

ធានៈ បាទ! ដល់ឆ្នាំ៨៦ដែលវាយយើងនៅអ៎ ១០០១ហ្នឹង រួចអស់ បានមកបំបែក៨០២ ។ ៨០២ មានឈ្មោះ ឆន ។

ជនៈ ឆននេះគាត់ដឹកនាំ បាទ! មូលហេតុអីបានជាគាត់បំបែកកាលហ្នឹង?

ធានៈ រឿងថាបំបែកនេះដើម្បីបែកមុខសញ្ញាគ្នាធ្វើការ ពង្រីកការដឹកនាំ នេះតាមការយល់របស់ខ្ញុំ ។ ដល់ពេលបំបែកមុខសញ្ញា បំបែកការងារដឹកនាំនេះទៅដើម្បីអង្គភាពមួយៗ ជ្រើសរើសកម្លាំងដោយខ្លួនឯងមួយជំនាន់ហ្នឹងណា ។ ដល់ចឹងកម្លាំងចុះធ្វើការងារតាមភូមិចឹង ក៏យើង

អប់រំប្រជាជនតាមភូមិចឹងទៅ ខ្លះគេមាននិស្ស័យអីចង់មកបម្រើជាតិក៏គេមកជាមួយយើងទៅ ។ ប៉ុនជិនាន់ឆ្នាំ៨៦,៨៧,៨៨ ហ្នឹងនិយាយរួមប្រជាជនសឹងទូទាំង លះបង់កូនចៅមកចូលរួមមកអន្តភាពជាមួយអតីតខ្មែរក្រហមហ្នឹងណា ។ ដោយមូលហេតុគាត់ឃើញការរស់នៅរបស់អតីតខ្មែរក្រហមមិនមានការខុសឆ្គងអី ភាគច្រើនល្អមិនទៅប៉ះទង្គិចផលប្រយោជន៍បងប្អូន រស់នៅទីណាជួយកិច្ចការគេនៅទីហ្នឹង គាត់គោរពស្រលាញ់ទៅតាមហ្នឹងដែរ ។

ថន: ចុះពូចាប់ពីប៉ៃតនេះពូមក៨០២វិញ?

ធាន: ចុះមក៨០២ជាមួយ ឆន ។

ថន: ចុះសុន សេន គាត់គ្រប់គ្រងម៉េច?

ធាន: សុន សេន មួយសារហ្នឹងគាត់ជាគណៈ អ៊ំជាបញ្ជាការរួម ។

ថន: បញ្ជាការរួម?

ធាន: បាទ! បញ្ជាការរួមទូទាំងប្រទេស ដូចថាពេលឥឡូវដូចលោក ទា បាញ់ អីចឹងណា ។

ថន: ចឹងគាត់គ្រប់គ្រងទាំងអស់?

ធាន: គ្រប់គ្រងទាំងអស់ផ្នែកកងទ័ព ។ តាំងពី១០០១ រហូតដល់យើងសមុទ្រ ខ្សែបន្ទាត់ព្រំដែនទាំងអស់ ។

ថន: កោះកុង?

ធាន: បាទ!

ថន: ចុះតាម៉ុកអីគាត់នៅឯណាដែរ?

ធាន: មួយជំនាន់ហ្នឹង តាខៀវ អ៊ំគាត់ទៅទទួលផ្នែកខាង១០០១នោះ ហើយយើងនៅរាល់ថ្ងៃនេះផ្នែកខាងតាម៉ុក អាហ្នឹងហៅថា១០០៣ ដល់ទៅលិចចេះទៀតទៅហៅថាឈ្មោះ តាមលំដាប់គេចឹងទៅណា ខ្ញុំភ្លាប់ពុំបានទេ ។

ថន: ចឹងកាលនោះខាងតាខៀវឈរជើងនៅនោះតែម្តង?

ធាន: បាទ!

ថន: ចុះនៅហ្នឹងថាមានវាយខ្លាំង ខាងវៀតណាមវាយដល់រុញឲ្យចូលទៅដល់ថៃតែម្តងនៅឆ្នាំប៉ុន្មានពូ?

ធាន: នៅឆ្នាំ ១៩៨៥ ។

ថន: ៨៥?

ធាន: បាទ!

ថន: មុនបញ្ចូលលឲ្យទៅជាកងពល៨០២?

ធាន: បាទ!

ថន: វាយខ្លាំងហ្នឹងអ៎ ពូអាចរៀបរាប់បានទេពូ?

ធាន: វាយពីជំនាន់ឆ្នាំ ម៉ុំ៣ គេថាកាលមួយជំនាន់ហ្នឹង១០០១ណាស់ គឺថាវាយខ្លាំងណាស់ ព្រោះអីវាយបែកបាកជំនាន់លោករឿនហ្នឹង តា សុន សេន ហ្នឹងគឺថាបែកខ្ចាត់ខ្ចាយអស់ហើយ ។ គិតថាចាប់ប្រជាជនក៏បានមួយចំនួនច្រើនដែរ ។ ដល់ចឹងទៅប្រជាជនក៏រដ្ឋ និងរដ្ឋ និយាយរួមខាង ១០០៣ហ្នឹង មាន តាម៉ុក ដល់ចឹងទៅក៏ដឹកកម្លាំងពីកើតហ្នឹងមកស្នាក់នៅយើង ១០០៣ជាមួយតាម៉ុកនេះ ។

ថន: បញ្ជូនពីខាងនេះមក?

ធាន: បាទ! ព្រោះនៅទីនោះវាបែកបាក់អស់ហើយ ។ ហើយខាងយើង ១០០៣ ខាងតាម៉ុក គ្រប់គ្រង ក៏វាយបែកបាកដូចគ្នា ប៉ុនគ្រាន់តែថាគេនេះ គេជាប់ដីថៃ ចឹងទៅភៀសខ្លួនចូលដីថៃ ដល់ពេលមកកម្លាំងជុំគ្នា បានមកចាប់ផ្ដើមរៀបរយវាយតាមព្រំដែននេះវិញ បានយើងវាយតាមជួរជើងខ្នងភ្នំ បានរំដោះទីតាំងណាណីបានខ្លះ រំដោះអន្លង់វែង តាមកម្លាំងបេះតែចុះមក ទាំងប្រជាជនទាំងអីមក កងទ័ពអីមក កងទ័ពបេះតែរុញទៅមុខ ប្រជាជនទៅតាមក្រោយទៅ ។

ថន: ប្រជាជនទៅតាមក្រោយ?

ធាន: បាទ!

ថន: ចុះដល់ពេលវាយបែក ៨៥ហ្នឹងដកប្រជាជន ដកទាំងកងទ័ព ឬមួយដកប្រជាជន?

ធាន: ទាំងកងទ័ព ទាំងប្រជាជនទាំងអស់ ១០០១ហ្នឹងណា ។ នៅមិនបានទេ ព្រោះគ្រាប់ផ្លោងសឹងតែ៥ម៉ែត្រមួយហើយបែងក្រឡា ។

ថន: ចុះនោះថាមានជំរុំមួយពូ ១០០១ហ្នឹងថាមានជំរុំ?

ធាន: បាទ! មុនមានជំរុំកុមារតាំងពី៨០មករហូតដល់ឆ្នាំ៨៥ វាយធំដែលវៀតណាមវាយធំ ដែលយើងឈរជើងនៅបាន ព្រោះអីវៀតណាមវាយបានផងពីទល់មុខផង ដល់ចឹងមិននៅបានទេ ។

ថន: គេហៅជំរុំអីវិញ?

ធាន: ១០០១ដដែរ ។

ថន: ជំរុំ១០០១! នៅក្នុងទឹកដីខ្មែរ ឬក្នុងទឹកដីថៃ?

ធានៈ   នៅក្នុងទឹកដីខ្មែរ នៅជាប់ព្រំដែនថៃ ជាប់អ៊ំដីខ្មែរ ជាប់ដីថៃ ជាប់ដីលាវ ។ ដែលហៅថាមុំ៣ សព្វថ្ងៃនេះណា ។ ប៉ុន្តែមុំ៣សព្វថ្ងៃយកមកដាក់ ពីដើមកាលមុនកន្លែងដែលពួកតាម៉ៅនៅហ្នឹង មិនត្រូវទេ បើត្រូវអាកន្លែងទឹកចេញនេះ នៅភូមិទឹកចេញ ។

ថនៈ   ៨១ កាលហ្នឹងពូធ្លាប់ឈរជើងនៅហ្នឹង ឬក៏?

ធានៈ   ៨១វរសេនាធំ ដែលមកពីកើតនោះរួចអស់ហើយ ដល់ចឹងមកនៅតាមជងចម្រេះភ្នំ ជាប់ហ្នឹង ព្រំដែនលាវ ឬក៏ជាប់នៅព្រំដែនថៃ ព្រំដែនខ្មែរហ្នឹង ។ បាទ! ដល់ចឹងកន្លែង៨១ហ្នឹងមួយសារ ដែលមកនៅហ្នឹងមានតាម៉ៅគាត់គ្រប់គ្រង ៨១ ។

ថនៈ   ប៉ុន្តែបច្ចុប្បន្នគេយកកន្លែងនឹងជាមុំ៣?

ធានៈ   ដល់ពេលបច្ចុប្បន្នគេយកកន្លែងបន្ទាយតាម៉ៅហ្នឹង ធ្វើជាមុំ៣ ដល់ចឹងយកស្ទើរផុតអស់ហើយ ចេញចូលដីខ្មែរច្រើនណាស់ ។

ថនៈ   ចូលប្រហែលជាប៉ុន្មានគីឡូទៅ?

ធានៈ   ចូលប្រហែលជាច្រើនគីឡូដែរដីដើរ ៣,៤ម៉ោងដែលហ្នឹងណា ។ ពីទឹកចេញមកកន្លែងបន្ទាយ តាម៉ៅ មកមុំ៣(ស្តាប់ពុំបាន) អស់រលីង ។

ថនៈ   ពីមុននៅទឹកចេញទេពូ?

ធានៈ   មុំ៣នៅទឹកចេញហ្នឹងឯង ។

ថនៈ   កាលពេលជិនាន់ពូទៅដល់?

ធានៈ   បាទ! ប៉ុនខ្ញុំដែលនៅហ្នឹង អាកន្លែងដែលទឹកចេញហ្នឹងភូមិប្រជាជនមួយភូមិមកនៅហ្នឹង ដល់ មានផ្លូវឡាន ឧទាហរណ៍នេះមួយទន្លេល្អោចេះ មានផ្លូវឡើងកាត់ទន្លេល្អោមក មកទឹកចេញ បានមកចេះមក គេថាភូមិអាន បានមកចេះមកទៅភូមិពេទ្យអួមថៃ ដល់មកចេះមកកន្លែង គេថា ឋកន្លែង ទាហានលាវសណ៉ា មកចេះមកគេថាទាហានលោកបាងលោកអីហ្នឹងណា ។

ថនៈ   ពូអាចគូរបានទេបានទេ កន្លែងឈរជើងលើកមុន ហើយនឹង៨១ របស់តាម៉ៅគ្រប់គ្រងដែល តាម៉ៅគេយកដាក់ជាតំបន់មុំ៣សព្វថ្ងៃ ។ ពូអាចគូរបានទេ? គូរពេលពូទៅដល់ ។

ធានៈ   ភ្នំត្រង់ហ្នឹង វាបណ្តោយទៅកើតណ៉ា ដល់ចឹងទាល់តែយើងគូរទៅតាមលិចកើតដែរ?

ថនៈ   បាទ! ទៅតាមលិចកើតដែរ?

ធានៈ   គូរសាកល មើលមិនដឹងមិនដឹងខុសទេ ព្រោះអីអត់សូវបានដឹង(សើច) ។

ថនៈ   អត់អីទេ! យើងគ្រាន់តែចាំ គ្រាន់តែដៅចំណុច ។

ធានៈ   ទៅកើតចឹង ទៅកើតខាងនេះ ។ ឥឡូវយើងគូរតាមនលិចកើតចុះ ។

ថន: ទៅលើខាងជើង ហ៎ពូ?

ធាន: បាទ! អានេះចំណុចកើត យើងថាគួរតាមដងភ្នំសិន ដល់នេះវាផ្លូវឡាន អានេះហៅថា ដងទន្លេ ល្ពៅ អាហ្នឹងមកចឹង អានេះផ្លូវឡាន ដល់ចឹងទៅ ផ្លូវឡាននេះគេថាទឹកចេញអានេះផ្លូវបំបែក នេះមួយមកភូមិអាន អានេះទៅភូមិពេទ្យអួម ដីថៃ ។

ថន: ពូដាក់ឈ្មោះទឹកចេញតែម្ដងទៅ សរសេរអក្សរ ដាក់ទឹកចេញៗ ។

ធាន: ភូមិអាន!

ថន: អាហ្នឹងនៅខាងខ្មែរយើង ឬក៏នៅខាងលាវ?

ធាន: ភូមិអាននេះ គឺនៅក្នុងដីខ្មែរទេ ។ បាទ!ទឹកចេញនេះ វាជាប់នៅព្រំដែនថៃ ព្រំដែនលាវ ព្រោះផ្លូវនេះវាមានផ្លូវមួយទៅលោកបាងហ្នឹង ផ្លូវទៅពេទ្យអួម អានេះ តាមដងផ្លូវយើងនេះតាមដងទន្លេល្ពៅ អាតាមដងទន្លេល្ពៅនេះ គឺសហគមន៍ប្រជាជន ។

ថន: ចឹងម្ខាងនេះ ខាងខ្មែរ?

ធាន: បាទ!

ថន: ចូលទន្លេនេះ ។

ធាន: មកនេះ មកចេះមក មកភ្នំ វាទៅចេះវិញ ។ ដាក់មុំ៣ ដល់ចឹងទៅវាខុសគ្នាឆ្ងាយដែរ ។

ថន: កន្លែងនេះ កន្លែងតាម៉ៅ៨១?

ធាន: កន្លែង៨១ ។

ថន: ចឹងភ្នំរាល់ថ្ងៃដាក់ភ្នំអីវិញ?

ធាន: ដឹងគេដាក់ភ្នំអីបើគេដាក់ គេហៅមុំ៣ ។

ថន: បាទ! មុំ៣ ។ ប៉ុន្តែពូថាពីមុននោះនៅមុំណាពូ មុំ៣ហ្នឹង កាលពូទៅដល់?

ធាន: មុំ៣នេះៗ នៅនេះបានត្រូវ ។

ថន: អាហ្នឹងអាចាស់ ។ ប៉ុនអាចនិយាយថាកាល កាលពូឈរជើង នៅហ្នឹងមានខ្មែរមានអីនៅហ្នឹងតែម្ដងពូ?

ធាន: នេះភូមិខ្មែរ យើងទឹកចេញនេះ ។ អានេះភូមិអាននេះ អាហ្នឹងក៏ភូមិខ្មែរយើង ដល់មកឆ្ងាយដីប្រហែលជា៧,៨គីឡូដល់ភូមិពេទ្យអួម ។ ពេទ្យអួម ហ្នឹង ភូមិថៃហើយ ។

ថន: ប៉ុន្តែដូចថាមានស្នាមអី ពូទៅដល់ដំបូង ដូចថាមានបង្គោលមានអីស្លាកស្នាមព្រំដែនអីយ៉ាងម៉េច?

ធាន: អត់ៗ!

ថនៈ ដែលយើងអាចកំណត់ដូចថាកន្លែងហ្នឹងជាព្រំដែនពីមុនមក តាមពូសង្កេតឃើញ?

ធានៈ អត់មានឃើញបង្គោលស្លាកផង ប៉ុន្តែជំនាន់ហ្នឹងមកនៅក្រោយគេ យើងមិនចាប់អារម្មណ៍រឿងថាត្រឹមប៉ុន្មានព្រំដែនៗ ប៉ុនភាគច្រើនគេនិយាយត្រង់ហ្នឹងឯង ។ នៅម្តុំទឹកចេញនេះឯង ម្តុំ៣ដែលជាប់ថៃ ជាប់លាវ ជាប់ខ្មែរ ។

ថនៈ ចឹងខាងយើងគេហៅម្តុំ៣ ចុះខាងគេកាលហ្នឹងគេហៅម្តុំ៣ដែរ?

ធានៈ គេហៅម្តុំ៣ដូចតែគ្នា ។

ថនៈ ខាងថៃក៏ហៅម្តុំ៣ ខាងលាវក៏ហៅម្តុំ៣?

ធានៈ បាទ! បើតំបន់ចែកទឹកចែកដីអាហ្នឹងហើយ ។ ប៉ុនក្រោយឡើយគេធ្វើផ្ទះពួកអន្តភាពហ្នឹង គេនិយាយថា គេដាក់បន្ទាយតាម៉ៅ៨១ហ្នឹង ដាក់ម្តុំ៣ ។

ថនៈ ប្រហែលជាប៉ុន្មានគីឡូពីនេះ?

ធានៈ ទៅហ្នឹង ប្រហែលខ្ទង់៧,៨គីឡូ ទៅ១០គីឡូហើយតាមមើល ។

ថនៈ ឆ្ងាយដែរ!

ធានៈ បាទ!

ថនៈ ចឹងសព្វថ្ងៃនេះ នៅខាងនេះទេ?

ធានៈ សព្វថ្ងៃនៅនេះទេ!

ថនៈ ពូធ្លាប់ទៅទៀតទេ ក្រោយមក?

ធានៈ ខ្ញុំអត់ដែរបានទៅទេ ។ ប៉ុន្តែ តាមសួរគេអ្នកនៅហ្នឹង អ្នកធ្លាប់នៅចាស់ពីមុនជាមួយគ្នា ដល់សួរទៅគេថាដាក់នៅបន្ទាយតាម៉ៅ ។

ថនៈ ចឹងធ្វើព្រំដែននៅនេះវិញ?

ធានៈ បាទ! ព្រំដែននៅនេះ ដល់ចឹងដាក់ម្តុំ៣ទៅហ្នឹង យើងវាបាត់ដីនេះ ១០គីឡូវាបាត់អស់រលីងតែម្តង ។

ថនៈ ភ្នំនេះគេហៅភ្នំអី? ជួរភ្នំដងរែកដែរ ឬយ៉ាងម៉េច?

ធានៈ នេះៗ តាមដងទន្លេល្អៅ ។

ថនៈ អូ៎! ទន្លេល្អៅ ។

ធានៈ នេះតាមដងភ្នំនេះ ។

ថនៈ នេះភ្នំដងរែកអីពូ?

ធានៈ បាទ! ភ្នំដងរែក ៗ ថាកន្លែងនេះ កន្លែងតាម៉ៅនេះ កន្លែងនេះគេហៅមួយជំនាន់ខ្មែរក្រហមនៅ
អាម្តុំនេះគេថាម្តុំផ្ទះភ្ញៀវ ។

ថនៈ ផ្ទះភ្ញៀវ?

ធានៈ បាទ! នៅម្តុំផ្ទះភ្ញៀវ ។

ថនៈ បាទ! ខាងនេះ ខាងកើតអីចូ?

ធានៈ នេះខាងនេះកើត ៗ ទេ! កើតនេះអូន! កើតខាងតាម៉ៅ ។

ថនៈ អានេះខាងជើង ណ៎ពូណ៎?

ធានៈ បាទ!

ថនៈ ចឹង! ឥឡូវសព្វថ្ងៃមកដល់នេះវិញ?

ធានៈ បាទ! សព្វថ្ងៃគេយកមកដាក់នេះវិញ ។

ថនៈ បាទៗ!

ធានៈ ចឹងបានថាវាសឹកភ្នំវិញអស់ហើយ ។

ថនៈ អានេះភ្នំដែរណ៎ពូណ៎?

ធានៈ បាទ! សុទ្ធតែភ្នំហើយ តាមតំបន់ភ្នំហើយ ព្រោះថាអានេះវាទន្លេនេះភ្នំវាជតចូលក្នុងចេះណ៎
ភ្នំតាម៉ៅ ហើយភ្នំនេះរសាកមកចេះវិញ ។

ថនៈ ជាផ្លូវពូ?

ធានៈ បាទ! នេះជាផ្លូវ ប៉ុនផ្លូវជំនាន់តាខៀវគាត់ធ្វើ ។

ថនៈ បាទ! សុន សេនធ្វើ ។ អាហ្នឹងភ្ជាប់ទៅដល់ស្រុកអីវិញ?

ធានៈ ខាងក្រោមហ្នឹងមានតែស្រុកឆែប ។

ថនៈ ចុះពូ យើងដកពី១០០១ចេញមកហ្នឹង អានេះគឺចោលហើយ អត់មាននរណានៅទេ?

ធានៈ ចោលហើយ! អត់មាននរណានៅទេ ។

ថនៈ ដកចេញប្រជាជនមក ៗ មកនៅនេះមកនៅម្តុំណា មកនៅ១០០៣?

ធានៈ មកនៅយើង១០០៣ នៅភូមិថៃហ្នឹង គឺថាភូមិ គេថាភូមិដងទង់ ។

ថនៈ ភូមិដងទង់! នៅស៊ីសាកេត?

ធានៈ ទេ! មិនដឹងទេ! ភ្លេចបាត់ហើយ ។

ថនៈ ខេត្តស៊ីសាកេត ភូមិដងទង់ ។ មកដល់ឆ្នាំប៉ុន្មាន ៨៥តែម្តង?

ឆានៈ ៨៥ ខែ៥ ខែអីហ្នឹង ។ ដល់ក្រោយមកទើបគេដកចេញពីដងទង់មកលិចនេះវិញ ផាកមកពីលិចមកភូមិចងក មកនៅបានតែមួយឆ្នាំទេ ។

ថនៈ ១ឆ្នាំ មកភូមិចងកវិញ ។ ភូមិចងកនៅខាងថៃតាពូ?

ឆានៈ ខាងថៃ ។

ថនៈ កាលហ្នឹងយើង សុំខាងថៃនៅ ឬមួយយ៉ាងម៉េច ទំនាក់ទង?

ឆានៈ អាហ្នឹងខាលើៗសុំ ដូចទិញដីគេនៅចឹង ។

ថនៈ ពីណាទិញពូ?

ឆានៈ បើមិនតាទិញ ក៏តាខៀវទិញដែរ ។ ទិញរបៀបទិញយើងស្នាក់នៅ ដល់យើងចេញយើងប្រគល់ឲ្យគេវិញ ។ ប្រទេសថៃគេមិនឲ្យយើងជ្រកកោនស្រួលៗទេ បើមិនផលប្រយោជន៍ដល់គេ ។

ថនៈ អាហ្នឹងជាជំរុំ ឬក៏ជាទីតាំង?

ឆានៈ អាហ្នឹងជាជំរុំក៏ថាបាន ជាទីតាំងក៏ថាបាន ព្រោះអីភាគច្រើនជាគ្រួសារកងទ័ព ។

ថនៈ ចុះប្រជាជន?

ឆានៈ ប្រជាជន គាត់នៅចំរុះនៅហ្នឹងដែរ?

ថនៈ នៅចំរុះនៅហ្នឹងដែរ?

ឆានៈ បាទ! នៅចំរុះ ។

ថនៈ ចំរុះនៅជាមួយទ័ព ឬក៏ដាច់ដោយឡែក ។

ឆានៈ នៅចំរុះ ប៉ុនគ្រាន់តែថានៅក្នុងវង្វង់នៅហ្នឹងវាមានប្រជាជន ប៉ុនប្រជាជនរស់នៅមួយផ្នែកប្រជាជនទៅ កន្លែងគ្រួសារកងទ័ពតាមអង្គភាពនីមួយៗ តាមអង្គភាពមួយៗនោះទៅ ។

ថនៈ គេហៅជំរុំអីនោះវិញ?

ឆានៈ បើជំនាន់ហ្នឹង គេដាក់អើនៅភូមិដងទង់ គេហៅដងទង់ទាំងអស់ ។ ដល់ពេលចេញពីអាហ្នឹងទៅចងក! គេថាចងកទាំងអស់គ្នាតែម្តងទៅ ។

ថនៈ ចម្ងាយប៉ុន្មានពីព្រំដែនបច្ចុប្បន្ន?

ឆានៈ ដីអើប្រហែល៣០គីឡូ!

ថនៈ កាំភ្លើងធំបាញ់ដល់?

ឆានៈ កាំភ្លើងធំបាញ់ដល់ ។

ថនៈ ពូស្នាក់នៅហ្នឹង ដូចថានៅកងណា យើងនៅកងហ្នឹងដដែរ ហើយមាននៅហ្នឹង ឬក៏ចល័តធ្វើសកម្មភាពធអីខាងក្នុងយ៉ាងម៉េចដែរ?

ធានៈ ទេ! បើថារឿងថាមូលដ្ឋានអាហ្នឹង ប៉ុនដែលដាក់ស្តែងរៀបចំធ្វើការទូទាំងប្រទេសនៅក្នុងទឹកដីខ្មែរ តាមអង្គភាពមួយៗ តាមមុខសញ្ញាមួយៗ ដូចអង្គភាព៨០២ ឈរជើងនៅកំពង់ធំចឹងទៅ ។ បាទ! ដូជថា៦១២ របស់លោកហឿននេះ គាត់ឈរជើងនៅព្រះវិហារទៅ ។

ថនៈ កំពង់ធំពូនៅម្តុំណាណាពូ ពីណាទៅណាពូ?

ធានៈ នៅមួយជួរស្រុកសន្ទុក ស្រុកសណ្តាន់ ស្រុកកំពង់ស្វាយ ។

ថនៈ ចុះមេបញ្ជាការពូឈ្មោះ ឆន ។

ធានៈ តា ឆន បាទ!

ថនៈ ចុះពូចុះឡើងពីនេះទៅឈរជើងនៅកំពង់ធំ?

ធានៈ បាទ!

ថនៈ ប៉ុន្មានឆ្នាំ នៅហ្នឹងរហូតដល់?

ធានៈ មើលនៅតាំងពី៨៥,៨៦ហ្នឹងមករហូតដល់យើងសមាហរណកម្មបញ្ចូលគ្នា ៩៨ ។

ថនៈ ៩៨?

ធានៈ បាទ!

ថនៈ ហើយថាបានឈរជើងមួយជួរភ្នំដងរែកនេះ ពេលពូចល័ត ពូនៅតាមភ្នំហ្នឹងដែរ?

ធានៈ បាទ! ដល់ពេល ឧទាហរណ៍ថានៅតាមខ្សែក្រវាត់ព្រំដែនហ្នឹងណា ជំនាន់ហ្នឹងថាយួនវារៀបចំផែនការជួរក-៥ ដល់ចឹងទៅវាតាមខ្សែបន្ទាត់ ដូចថាដាក់មីនស្អេកស្កះណាស់ កម្លាំងក៏ស្អេកស្កះដែរ ។ ដល់តាមកខ្សែបន្ទាត់ព្រំដែន ដែលកម្លាំងយើងមកពីនោះមកណា ដល់ចឹងយើងនៅប្រចាំការនៅនោះជាប់ដែរ ។ ប្រហោងកន្លែងណាយើងនាំកម្លាំងតាមហ្នឹង ដើម្បីចុះរុញចូល ទៅក្នុងៗណា ទៅខាងព្រៃវែង ស្វាយរៀងចេះចុះទៅ ទៅកំពង់ធំ មកខាងសៀមរាបអាហ្នឹងដាក់ស្តែងនៅតាមហ្នឹង ទៅខាងខេត្តព្រះវិហាហរអីចឹងទៅ ។

ថនៈ ចឹងពូនៅខាងហ្នឹង យើងអត់ដែលមានបញ្ហាជាមួយថៃទេ?

ធានៈ ពីជំនាន់ហ្នឹងមិនមែនថាវាអត់សោះទេ មានដែរគ្រាន់តែថាកាលដោះស្រាយវាបាន និយាយគ្នាបាន ។

ថនៈ ដោះស្រាយយ៉ាងម៉េចទៅពូ?

ធានៈ ដោះស្រាយតាមនិតិវិធី អ្នកដឹកនាំខាងលើៗ បើយើងផ្ទាល់ជាទាហានៗនិយាយពុំចូលគ្នាទេ ។

ថនៈ ឧទាហណ៍ថា ព្រំដែនអីចឹងណា ចឹងយើងអត់មានថាខាងណាច្បាស់លាស់ទេពូ?

ធានៈ ព្រំដែនហ្នឹង និយាយរួមដូចថាបងៗដែលតំណាងដឹកនាំកងពលក្នុងសមរភូមិរបស់គាត់ ច្បាស់លាស់របស់គាត់ ប៉ុនក្រោមៗទេដែលមិនអារម្មណ៍នោះណា ។ ធម្មតាខាងលើពិតមែនតែរស់នៅលើដីគេ ប៉ុនរឿងព្រំដែនគាត់សម្គាល់របស់គាត់ឯង ។ ដល់ថ្ងៃក្រោយស្រុកឯករាជទៅឥឡូវ ឧទាហរណ៍ថាឈ្នះតែនៅក្នុងខ្មែរក្រហម ចុះបើខ្មែរក្រហមមិនគិតគូពីព្រំដែនជំនាន់ហ្នឹងមកពេលថ្ងៃក្រោយទៅមានកស្តុតាងអីទៅជាមួយគេ អត់! ខាងលើគាត់ចាប់អារម្មណ៍ហើយមិនអត់ទេ តាមការយល់របស់ខ្ញុំទេណា ។

ថនៈ ប៉ុនថាដូចជាមួយជួរត្រពាំងប្រាសាទនេះ អន្លង់វែងនេះពីចាស់ ព្រំដែនសព្វថ្ងៃជា ព្រំដែនចាស់ដែលខ្មែរក្រហមធ្លាប់នៅគ្រប់គ្រង ។ អាហ្នឹងចាស់ ឬក៏ថ្មី?

ធានៈ និយាយរួមភូមិ ស្រុកត្រពាំងប្រាសាទអត់មានចាស់ទេ គឺសុទ្ធតែរៀបចំប្រព័ន្ធថ្មីទាំងអស់ មានអន្លង់វែង អាហ្នឹងមានចាស់ខ្លះ ដូចជាភូមិផ្អាវ ភូមិឫស្សី ភូមិផ្កូវ ភូមិអន្លង់វែង និងសុទ្ធតែពួកចាស់! ហើយឃុំរមៀត រមៀតដែលយើងទៅអាទំនប់ក្រោមនោះក៏ភូមិចាស់ដែរ ។

ថនៈ ហើយចុះមួយជួរជនាអាព្រំដែនហ្នឹងពូ និយាយថាមួយជំនាន់ហ្នឹងពូឆ្លងកាត់តាមហ្នឹងដែរ ឬតាមផ្លូវ ដូចថាវានៅដូចថានៅរាល់ថ្ងៃហ្នឹង អាកន្លែងដូចថាយើងឈរជើងសងខាងហ្នឹង ដូចដែលអ៊ីពូឆ្លងហ្នឹង ឬមួយភ្លែកពីគ្នា?

ធានៈ មួយជំនាន់ផ្លូវក-៥ ហ្នឹងតាមការពីនិត្យមើលរបស់ខ្ញុំគឺធ្វើនៅក្នុងដីយើងទាំងអស់ ។

ថនៈ ចូលមកខាងយើង?

ធានៈ ចូលមកដីយើងទាំងអស់អត់មានជំពាក់ជំពិនជាមួយដីថៃទេ ព្រោះព្រំដែន នៅកន្លែងខ្លះយើងក៏ដើរមានបិត មានបង្គោលឡាក់ ពីបង្គោលឡាក់មកអាកន្លែងផ្លូវក-៥ ដែល រដ្ឋាភិបាលយើងរាល់ថ្ងៃដូចថាយួនចុះ បាទ! ព្រោះអីផ្លូវក-៥ ហ្នឹងក៏វានៅក្នុងទឹកដីយើងទាំងអស់ ព្រោះពីបង្គោលឡាក់មកវាឆ្ងាយ ។ ដល់ចឹងវាត្រូវការបាត់បង់ដីច្រើន ។ ដូចប្រាសាទព្រះវិហារចឹងពីដើមមកអាកន្លែងជិតប្រាសាទ ថាផ្ទះក្រហមហ្នឹងណា អាហ្នឹងពីដើមឡើយសុទ្ធតែយើងរស់នៅដើមស្វាយដើមខ្នុរសុទ្ធតែរបស់យើងដាំទេ ។

ថនៈ ដើមស្វាយ ហើយខ្នុរដែលសល់រាល់ថ្ងៃហ្នឹងពូ?

ធានៈ ហ្នឹងសុទ្ធតែរបស់យើងដាំ ។

ថនៈ ផ្ទះហ្នឹងពូដឹងថាសាងសង់ឆ្នាំប៉ុន្មានទេពូ ផ្ទះក្រហមហ្នឹង?

ធានៈ ផ្ទះក្រហមហ្នឹងក្តាប់អត់បានដែរ ព្រោះក្រោយឡើងដែលចូលក្នុងរដ្ឋាភិបាល មិនដឹងថាប៉ុន្មានអីថា ប៉ុន្មានក៏មិនដឹងសាងពីឆ្នាំណាមកឆ្នាំណា ។ ប៉ុន្តែដែលជាក់ស្តែងដែលថាប្រាសាទព្រះវិហារ ខ្ញុំឡើងទៅប្រាសាទហ្នឹងឃើញមានផ្លូវកៅស៊ូដល់អូរដើងប្រាសាទនេះ ។

ថនៈ ពូឡើងទៅឆ្នាំប៉ុន្មានពូ?

ធានៈ ឆ្នាំ៩៨ ដែលព្រឹត្តិការណ៍ដំបូងហ្នឹង ។

ថនៈ ៩៨ ពូឃើញថ្នល់កៅស៊ូ?

ធានៈ បាទ! អាថ្នល់កៅស៊ូ សឹងតែមកដល់អូរគេស្រាស់បន្ទាលួស មកដល់អូរដើងប្រាសាទនេះនៅជើងជណ្តើរយើងនេះ ។

ថនៈ មកដល់អូរ?

ធានៈ បាទ!

ថនៈ ចុះបកមកវិញខ្ញុំសម្ភាសន៍ពូ ឈិន គឹមថុង គាត់ថាប្រាសាទស្រុក ថាគាត់ទៅ៩៩ គាត់អត់ទាន់ឃើញនេះទេ អត់ទាន់ឃើញផ្លូវកៅស៊ូទេ ។

ធានៈ ចឹងបានខ្ញុំទើបព្រឹត្តិការណ៍ប្រាសាទព្រះវិហារជាមួយថៃទេដែលខ្ញុំទៅឃើញទិដ្ឋភាពជាក់ស្តែង ពីមុនមកអត់ដែលឃើញទេ ប៉ុនតាមសួរបងៗឈរជើងនៅហ្នឹង គាត់ថាទៅខាងណោះប្រាសាទក្រហមទៀត ផ្ទះក្រហមហ្នឹងទៀតណា ។

ថនៈ ទៅខាងមុខហ្នឹងទៀត ជុតហ្នឹងទៀត?

ធានៈ ហ្នឹងហើយ អាហ្នឹងដីយើង ។ ប៉ុនឥឡូវវាមកដល់អូរនេះហើយ ចែកដីត្រឹមអូរនេះ សូម្បីតែយើងធ្វើផ្លូវឡើងក៏វាវាយយើងដែរ អាវាយគ្នាធំហ្នឹង អារឿងយើងធ្វើផ្លូវហ្នឹងឯង ។

ថនៈ ចឹងផ្ទះក្រហមហ្នឹង ផ្ទះពីណាសាងសង់ពូបើតាមពូដឹង?

ធានៈ ខ្ញុំក្តាប់អត់បាន មិនដឹងជាពីជំនាន់មុនយើងនៅហ្នឹង ប៉ុនមិនដឹងយើងករសាង ឬជាថៃកសាងទេ ។

ថនៈ ជំនាន់មុនហេ៎?

ធានៈ បាទ!

ថនៈ ជំនាន់មុនហ្នឹងប្រហែលជាឆ្នាំប៉ុន្មាន?

ធានៈ ដែលវាយពីរដ្ឋាភិបាលបានហើយណា ដឹងឆ្នាំប៉ុន្មានទេ ចាំមិនបានទេ ព្រោះអីមិនមែនមុខសញ្ញាយើងធ្វើការណា បើសួរបងហឿនដែលខ្ញុំប្រាប់ហ្នឹងវាអាច គាត់យល់ហើយព្រោះគាត់ឈរជើងជាប់រហូត រហូតដល់សមារណកម្មនោះបណ្តោយ ។

ថន: ចឹងលោកពូគ្រាន់តែដឹងតាមរយៈធ្លាប់ឈរជើងនៅហ្នឹង ផ្ទះក្រហមនេះធ្លាប់ធ្វើទាហាន?

ផាន: គេធ្លាប់ធ្វើនៅហ្នឹង បាទ!

ថន: កងពល កងទ័ពខ្មែរក្រហម?

ផាន: ខ្មែរក្រហម ។

ថន: កងពលលេខប៉ុន្មានពូធ្លាប់ឈរជើងនៅហ្នឹង?

ផាន: កងពល៦១២ ។

ថន: កងពល៦១២?

ផាន: បាទ! មានបងហឿនដឹងនាំ ។

ថន: ហ្នឹងកងពលអីលោកពូ?

ផាន: បាទ!

ថន: ៦១២ ហឿន! គាត់ដឹកនាំផ្ទាល់?

ផាន: បាទ! គាត់ដឹកនាំផ្ទាល់នៅហ្នឹងបណ្ដោយ ។

ថន: ចុះខាងថៃអីអត់មានមកឈរជើង ឈរអី?

ផាន: ពីដំនាន់ហ្នឹងយើងនៅ វាអត់មានមកក្បែរយើងទេ បើតាមខ្ញុំយល់ទេណា បើតាមអ្នកកាលនៅហ្នឹងគេធ្លាប់និយាយប្រាប់ណា បាទ! ប៉ុនដល់ក្រោយឡើង សមាហរណកម្មមក មិនដឹងជាយ៉ាងទេ ខ្ញុំមិនដឹងដែរ ទើបតែមកព្រឹត្តិការណ៍ប្រាសាទព្រះវិហារទៅយកអង្គភាពដែលយើងសមាហរណកម្ម មិនរៀបបញ្ចូលអើ អនុ្ទង់វែងគេដាក់កងពលធំ២៣ ហើយត្រពាំងប្រាសាទកងពលធំ២៤ ។

ថន: អនុ្ទង់វែង២៣?

ផាន: បាទ!

ថន: អនុ្ទង់វែង២៣!

ផាន: ដាក់ត្រពាំងប្រាសាទ២៤ ។

ថន: ២៣ហ្នឹងពីណាអ្នកគ្រប់គ្រង?

ផាន: អត់! ក្ដាប់អត់បាន ។

ថន: ចុះ២៤?

ផាន: ២៤ អ៊ុំង លាង ។

ថន: អ៊ុំង លាង! ក្រោយសមាហរណកម្មលោកពូ?

ធានៈ បាទ! ក្រោយសមាហរណកម្ម ។

ថនៈ ហើយមានទៀតទេពេលហ្នឹង គាពីរហ្នឹងទេ?

ធានៈ តែពីរហ្នឹងទេ ។ ប៉ុន្តែក្រោយឡើង២៨ និង២៣នេះបញ្ចូលគ្នាទៀត ។

ថនៈ ទៅជាកងពលលេខប៉ុន្មាន?

ធានៈ កងពលលេលខ៨៣ ។

ថនៈ កងពលលេខ៨៣!

ធានៈ បាទ!

ថនៈ ៨៣ នរណាគេអ្នកគ្រប់គ្រង?

ធានៈ ៨៣ មាន យឹម ពឹម រាល់ថ្ងៃកងពលលេខ៨ហ្នឹង ។

ថនៈ សព្វថ្ងៃលេខ៨ ។

ធានៈ បាទ!

ថនៈ ដូរពីឆ្នាំណា មកកងពលលេខ៨?

ធានៈ មើលក្រោយពីប្រាសាទ ខ្ទង់ឆ្នាំ ដូចបាន៩ឆ្នាំ ហើយមើលទៅ ។ ក្រោយពីនេះហើយដូចចំ កងពលធំលេខ៣ហ្នឹង មានខាងកងពលលោក ស្រី ដឹក ហ្នឹង ហើយនឹងជាមួយ៨៣បូកបញ្ចូល គ្នាទៅជាក់កងពលធំលេខ៣ ។

ថនៈ កងពលលេខ៣ហេ៎?

ធានៈ បាទ!

ថនៈ បូកបញ្ចូលជាមួយ៨៣របស់ យឹម ពឹម នេះស្រី ដឹក?

ធានៈ បាទ!

ថនៈ បូកហើយបានជាកងពលលេខ៨?

ធានៈ បាទ!

ថនៈ កងពលលេខ៨ សព្វថ្ងៃពីណាលោកតូ?

ធានៈ យឹម ពឹមដដែរ ។

ថនៈ យឹម ពឹម ដដែរ! ចឹង ស្រី ដឹកគាត់?

ធានៈ គាត់ទៅជាមេបញ្ជាការកងពលធំ ។

ថនៈ ចុះយឹម ពឹម គាត់?

ធានៈ គាត់នៅកងពលតូចលេខ៨ ។

ជនៈ  កងពលតូចលេខ៨ យឹម ពឹម! ស្រី ដឹក មេញ្ញោកា?

ធានៈ  មុនកងពល១២ ។

ជនៈ  ស្រី ដឹក មុននៅឯណា?

ធានៈ  កងពល១២, របស់រដ្ឋាភិបាល ។

ជនៈ  ដល់ពេលបញ្ចូលគ្នាជាមួយ!

ធានៈ  ៨៣ជាមួយវរៈព្រំដែនខ្លះ វរៈព្រំដែន មិនដឹងជាវរៈណាៗខ្លះទេ ដល់បញ្ចូលហ្នឹងទៅដាក់កងពលធំលេខ៣ហ្នឹង ។

ជនៈ  កងពលធំលេខ៣?

ធានៈ  បាទ!

ជនៈ  នេះចូលមកបានលេខ៣ ហើយបានចូលមកបូកបញ្ចូលគ្នាជាមួយហ្នឹងអ៎!

ធានៈ  ហ្នឹងហើយ៨៣ហ្នឹង ៨៣ហើយពួកវរៈព្រំដែនប៉ុន្មាន វរៈទៀតហ្នឹងក៏បញ្ចូលមកដាក់កងពលធំលេខ៣ហ្នឹង ។

ជនៈ  បាទៗ! ហើយសព្វថ្ងៃហ្នឹង គាត់នៅលេខ៣អីលោកពូ ស្រី ដឹក?

ធានៈ  គាត់នៅលេខ៣ គាត់នៅមេបញ្ជាការកងពលធំលេខ៣ ។

ជនៈ  ហើយ យឹម ពឹម គាត់នៅ?

ធានៈ  នៅកងពលតូចលេខ៨ ។

ជនៈ  កងពលតូច៨ វានៅក្នុងកងពលលេខ៣នេះដែរ?

ធានៈ  ក្នុងលេខ៣ដែរ ។

ជនៈ  លេខ៣នេះមានប៉ុន្មានកងពលលោកពូ?

ធានៈ  លេខ៣នេះ វាមានលេខ៧ លេខ៨ លេខ៩ មាន៣កងពល ។

ជនៈ  លេខ៨ពីណាគេអ្នកគ្រប់គ្រងពូ?

ធានៈ  អត់សូវស្គាល់ឈ្មោះដែរ ។

ជនៈ  គាត់អតីតអ្នកខ្មែរក្រហមដែរ ឬក៏មកពីខាងក្នុង?

ធានៈ  លេខ៧នេះៗ មកពីខាងអតីតរដ្ឋាភិបាល ។

ជនៈ  លេខ៩នេះ?

ធានៈ  លេខ៩នេះដកចេញពី លេខ៧ហ្នឹងខ្លះ ដកចេញពីលេខ៨ហ្នឹងខ្លះ ។

ជនៈ  ពីណាអ្នកគ្រប់គ្រងកងពលតូច?

ធានៈ លេខ៩នេះហេ៎?

ថនៈ បាទ!

ធានៈ អត់សូវស្គាល់ដែរ ។

ថនៈ ចឹងឈរជើងនៅអ៎ប្រាសាទព្រះវិហារហ្នឹង មានអ៎ហ្នឹងទេ ពេលជំនាន់ខ្មែរក្រហម?

ធានៈ ពេលជំនាន់ខ្មែរក្រហមទេ ពីមុនសម័យសមាហរណកម្ម ។

ថនៈ គាត់ឈរពីឆ្នាំណា ដល់ឆ្នាំណាពូដឹងទេ កងពលគាត់?

ធានៈ ខ្ញុំពុំបានចាំដែរ ។

ថនៈ ហ្នឹងកងពលហេ៎ពូ ៦១២នេះ?

ធានៈ បាទ! កងពល ។

ថនៈ កងពលធំ ឬក៏កងពលតូច?

ធានៈ វាអាចកងពលតូចទេ ជំនាន់ហ្នឹង ។

ថនៈ ហ្នឹងនៅចំណុះអីវិញលោកពូ កងពលលេខប៉ុន្មានបើតាមលោកពូដឹង?

ធានៈ អ៎ចំណុះអ៎ក្នុង១០០៣ នៅក្នុងតាម៉ុកទាំងអស់ ។

ថនៈ ១០០៣! មានប៉ុន្មានកងពលរបស់តាម៉ុកហ្នឹង?

ធានៈ ក្តាប់ពុំបានទេច្រើនណាស់ ។

ថនៈ ពីឆ្នាំណាពូមានដឹងទេ ដែលគាត់ឈរជើង?

ធានៈ អត់សូវចាំដែលខ្ញុំ ។

ថនៈ ប៉ុន្តែរហូតដល់សម័យសមាហរណកម្ម?

ធានៈ បាទ! ដែលវាយពីរដ្ឋាភិបាលបានហើយ មិនដឹងជាឆ្នាំប៉ុន្មាន ហើយដល់ពេលនេះទៅមិនដឹងចូលរដ្ឋាភិបាល អាហ្នឹងបានឈរជើង វាយពីរដ្ឋាភិបាលបានហើយ ។

ថនៈ ចឹងពេលដែលអំឡុងខ្មែរក្រហមនៅតាមបណ្តោយព្រំដែនហ្នឹង អត់មានបញ្ហាព្រំដែនដែរណា?

ធានៈ អត់ដែរទេ!

ថនៈ អត់ដែលមានជម្លោះព្រំដែនទេ?

ធានៈ អត់ទេ!

ថនៈ ខាងថៃអត់មានដែលមកនិយាយថាដូចថាមកកំណត់ដូចថាដាក់ទាហានឲ្យឈរជើង អត់មានទេ?

ធានៈ អត់មានទេ! និយាយរួមពីជំនាន់ហ្នឹង មិនដែលអើពើអារឿងព្រំដែននេះទេ ។ បានយើងនៅផ្លូវហ្នឹងហើយ យើងមកឈរជើងទៅហើយនាំខាតកម្លាំង(សើច) ទោះវានៅក៏នៅកម្លាំងតិចតួចដែរ ។ និយាយទៅពីជំនាន់ហ្នឹងវាហាក់ដូចជារបងឲ្យគេដែរ ។

ថនៈ ខាងថៃអីលោកពូ?

ធានៈ ចុះបើតាមព្រំដែន យើងនៅរហូតអីចឹងទៅ ទាហានរដ្ឋាភិបាលទៅយើងមិនដឹង បើយើងធ្វើការនៅហ្នឹងហើយ ។ ហើយដល់ចឹងវាអត់សូវហានអើពើប៉ុន្មានទេ ។ ឈរដែរវាឈរតាម ចំណុចៗណាដែលសំខាន់ៗនោះដូចជាផ្លូវអានម៉ា អាហ្នឹងវាឈរហើយ ។

ថនៈ ផ្លូវអានម៉ានៅណាវិញ?

ធានៈ ផ្លូវអានសេះហ្នឹងណា ។

ថនៈ អានសេះ!

ធានៈ ប៉ុនដូជថាខ្ញុំនិយាយថាអានម៉ាហ្នឹង ភាសាថៃទេ ប៉ុនខ្មែរយើងអានសេះហ្នឹងហើយ ព្រោះជំនាន់ហ្នឹងវារកស៊ីជាមួយខ្មែរយើងផងដូចជាប្រេង ដូចជាអីហ្នឹងណា វាបង្ហូរពីលើមក ។

ថនៈ ប៉ុនពូដែលទៅដល់អាមួយផ្លូវភ្នំប្រាសាទទេ មួយជំនាន់ហ្នឹង?

ធានៈ មួយជំនាន់ហ្នឹងខ្ញុំធ្វើការនៅតែតាមជើងភ្នំហ្នឹងឯង ដូចខទាហរណ៍ថាសភាពការណ៍រដ្ឋាភិបាលប្រុងមកវាយយកប្រាសាទព្រះវិហារវិញចឹងទៅ ដល់ពេលខ្ញុំឡើងមកពីក្រោមវិញមក មានកម្លាំងនៅស្នាក់ នៅនេះដល់ចឹងរៀបរយទៅជួយគេ ជួយអន្តរាគមន៍គេ ។

ថនៈ ហើយផ្លូវឡើងប្រាសាទហ្នឹង អត់មានទេកាលហ្នឹង?

ធានៈ ពីជំនាន់មុនហ្នឹងអត់មានទេ ទើបតែមកជំនាន់តាម៉ុកកាប់ហ្នឹងឯង ដែលផ្លូវហ្នឹងណា ។

ថនៈ ចឹងផ្លូវហ្នឹង តាម៉ុកអ្នកឈូសទេ ផ្លូវដែលយើងធ្វើសាងសង់រាល់ថ្ងៃកាត់វត្តកែវសិក្ខាគិរីស្វារៈ?

ធានៈ បាទៗ!

ថនៈ នោះ ជាផ្លូវចាស់ហ្នឹងរបស់តាម៉ុក គាត់ឈូសបាន?

ធានៈ ផ្លូវចាស់របស់តាម៉ុក ។

ថនៈ ចឹងជំនាន់នោះទាហានខាងខ្មែរក្រហមគាត់ឈរជើងនៅលើប្រាសាទហ្នឹង?

ធានៈ បាទ! ឈរជើងនៅលើប្រាសាទហ្នឹង ។ នៅលើប្រាសាទហ្នឹង ដូចថាផ្ទះក្រហមហ្នឹងក៏សុទ្ធតែខ្មែរយើងនៅហ្នឹង ។ ទើបតែសមាហរណកម្មហ្នឹងបានមកឃើញថាមានអើផ្លូវកៅស៊ូ មានផ្ទះក្រហម មានអីហ្នឹង ពីដើមគេហៅប្រាសាទក្រហមតែប៉ុណ្ណឹង ។

ថនៈ កន្លែងផ្ទះតាម៉ុក ហ្នឹងហេ៎?

ធានៈ អត់ទេ! អាកន្លែង ដែលខ្ញុំថាប្រាសាទក្រហម ផ្ទះក្រហមឥឡូវណេ៎! ពីដើមយើងហៅប្រាសាទក្រហមទីហ្នឹង មកឥឡូវគេហៅថាផ្ទះក្រហម ។

ថនៈ ចឹងពីមុនខ្មែរក្រហមគេហៅចឹងតែម្តង ហៅផ្ទះប្រាសាទក្រហមតែម្តង?

ធានៈ បាទ! ហៅផ្ទះប្រាសាទតែម្តង ។

ថនៈ ហ្នឹង! កាលមុនសមាហរណកម្មមែនទេ?

ធានៈ មុនសមាហរណកម្ម ។

ថនៈ ប្រហែលជាក្នុងអំឡុងឆ្នាំប៉ុន្មាន ពូចាំទេ?

ធានៈ មើលនៅហ្នឹងអាចខ្ទង់ អាច៩៦,៩៧,៩៨ ហ្នឹងតាមមើល ។

ថនៈ គេនៅជាប់ហៅប្រាសាទក្រហមនៅឡើយទេ?

ធានៈ បាទ!

ថនៈ ផ្លូវដែលតាម៉ុកគាត់ធ្វើហ្នឹងឡើងបានតែជាថ្មើរជើង ឬក៏អាចឡានអីចេញចូល?

ធានៈ ពីដំនាន់ហ្នឹងហេ៎?

ថនៈ បាទ!

ធានៈ ឡានឡើងបានតើ! ដែលព្រឹត្តិការណ៍ប្រាសាទព្រះវិហារហ្នឹង ឡើងតាមផ្លូវចាស់តាម៉ុក ឈូសពើយកន្លែងខ្លះ អាកន្លែងណារាងចោទទេរចឹងទៅគាត់ចាក់បេតុងដែរ ដល់កន្លែងណានេះហ្នឹងក៏បានតែមួយឈូសទេៗ អត់បានរៀបបេតុងទាំងអស់នោះទេ ។

ថនៈ អាហ្នឹងគាត់សាងសង់ដើម្បីអីវិញ បើតាមពូដឹង?

ធានៈ តាមខ្ញុំយល់សាងសង់ហ្នឹង ដើម្បីការពារប្រាសាទហ្នឹងដែរ ដើម្បីដឹងជញ្ជូនសេដ្ឋកិច្ច គ្រាប់រំសេវអីទៅលើប្រាសាទ ។

ថនៈ អត់មែននិយាយថាឈូសហ្នឹងដើម្បីដាក់ទីតាំងយោធា ដើម្បីងាយស្រួលវាយជាមួយរដ្ឋាភិបាលអីទេលោកពូ?

ធានៈ រឿងហ្នឹង ក៏វាជារឿងមួយដែរ រឿងសេដ្ឋកិច្ចក៏ជារឿងមួយដែរបើយើងមានតែទីតាំងអត់មានផ្លូវក៏យើងមិនធ្វើអីកើតដែរ សំខាន់រឿងសេដ្ឋកិច្ច ។ ជញ្ជូនគ្រាប់ ដឹកជញ្ជូនស្បៀង ជញ្ជូនកម្លាំង ដូចយើងរដ្ឋាភិបាលយើងរាល់ថ្ងៃចឹងទៅណា កាលព្រឹត្តិការណ៍ប្រាសាទព្រះវិហារដំបូងបើសិនជានេះអត់ទាន់កើតទេផ្លូវកៅស៊ូនេះតាមមើលតាមខ្ញុំយល់ទេណា អាហ្នឹងរដ្ឋាភិបាលអ្នករៀបចំផ្លូវកៅស៊ូខ្វែងខ្វាត់ ផ្លូវជាតិលេខ១១២អី ក៏រៀបចំជាផ្លូវកៅស៊ូដើម្បអី ក៏ដើម្បី ទី១ សេដ្ឋកិច្ច ទី២រឿងគ្រាប់រំសេវ ទី៣ ដើម្បីកម្លាំងចល័តចុះចល័តឡើង ដើម្បីវាស្រួល ។

ថន៖ ខាងខ្មែរ! ខាងទាហានឈរជើងនៅមុំផ្ទះក្រហមហ្នឹង រហូតដល់ឆ្នាំណាលោកពូ អាចដឹង ហើយដកចេញ ខាងថៃមកនៅណា?

ធាន៖ ទាល់តែសមាហរណកម្មដូចពូប្រាប់អំបាញ់មុនហ្នឹង ទាល់សមាហរណកម្មហ្នឹងឯង ។

ថន៖ បន្ទាប់ហ្នឹង ខាងថៃមកនៅផ្ទះក្រហម?

ធាន៖ ថៃមកនៅឆ្នាំណាៗ ខ្ញុំក្តាប់ពុំបានទេ ។

ថន៖ ប៉ុនខាងខ្មែរក្រហមដកចេញណា?

ធាន៖ ត្រឹមសមាហរណកម្ម៩៨ហ្នឹងណា ។

ថន៖ ៩៨?

ធាន៖ បាទ!

ថន៖ តាម៉ុកសាងសង់ផ្លូវហ្នឹង ប្រហែលជាខ្ទង់កៅជាងពូ?

ធាន៖ ខ្ទង់កៅជាងហើយ ។

ថន៖ ប្រហែលជាកៅប៉ុន្មាន?

ធាន៖ ខ្ទង់៩៧ កៅអីហ្នឹង ។

ថន៖ ពូ! និយាយថាពូ ផ្ទះក្រហម ទាហានខ្មែរក្រហមហ្នឹង ឈរផុតពីផ្ទះក្រហមហ្នឹងទៀតមែនទេ ពូ?

ធាន៖ បាទ! ឈរពីដើមគេហៅប្រាសាទក្រហម មកដល់ឥឡូវគេហៅផ្ទះក្រហម ពីដើមខ្មែរក្រហមនៅហ្នឹង ។ ដើមខ្នុរ ដើមស្វាយ ដាំបន្ថែបផ្ការហូប ហើយលើប្រាសាទហ្នឹងក៏កម្លាំងយើងឈរជើងនៅហ្នឹង ប៉ុន្តែដល់ពេលក្រោយសមាហរណកម្មទៅ ខ្ញុំក្តាប់ក៏ក្តាប់ពុំបានដែរ ព្រោះអីចូល រដ្ឋាភិបាលហើយ ទើបតែព្រឹត្តិការណ៍ឆ្នាំ ២០០៨ហ្នឹង ស្រាប់តែឃើញមានផ្លូវកៅស៊ូ ថាទាហានថៃគេនៅហ្នឹង ។

ថន៖ ២០០៨ហ្នឹង ពូទៅម្តងទៀត?

ធាន៖ បាទ! ដោយសារតែព្រឹត្តិការណ៍ឆ្នាំ២០០៨ ហ្នឹងមិនព្រឹត្តិការណ៍ប្រាសាទព្រះវិហារជាមួយថៃ វាឡើងមកដល់ប្រាសាទ មកដល់រុញកងទ័ពយើងប្រផាត់ប្រភឹងទាំងអស់គ្នាហ្នឹង ។ មិត្តភក្រ្តដែលមួយសារព្រឹត្តិការណ៍ទេថាពីដើមអញនៅកន្លែងប្រាសាទក្រហម ដល់ចឹងទៅឥឡូវមកណារបស់ថៃ មកណាមានផ្លូវកៅស៊ូគេនិយាយចឹងណាមិត្តភក្រ្តជាមួយគ្នាមួយសារព្រឹត្តិការណ៍ហ្នឹង ។

ថន៖ ចុះគាត់នៅទេ មិត្តភក្រ្តដែលនេះហ្នឹង?

ធានៈ មិតភក្ដ្រហ្នឹង គាត់នៅអន្លង់វែង ។

ថនៈ នៅអន្លង់វែង?

ធានៈ បាទ! ប៉ុនសួរតែមេៗទៅគាត់ដឹងហើយ ព្រោះអីគាត់ឈរជើងនៅហ្នឹងបានយូរ ហើយក៏គាត់បាននៅដែរ ។

ថនៈ ពូ! កាលជំនាន់នោះការឆ្នាំប៉ុន្មានដែរពូ?

ធានៈ ខ្ញុំហ៎?

ថនៈ បាទ!

ធានៈ ខ្ញុំយកគ្រួសារនៅ៨៥ហើយ ៨៥,៨៦ ។

ថនៈ មកយកនៅនេះទេ?

ធានៈ បាទ! មកយកនៅភូមិចង់ករ ។

ថនៈ នៅភូមិចង់ក, គ្រួសារពូឈ្មោះអីដែរពូ?

ធានៈ ឈ្មោះ ឌី ផល្លី ។

ថនៈ គាត់អ្នកនៅខាងណាដែរពូ?

ធានៈ ស្រុកកំណើតគាត់នៅស្ទឹងត្រែង ។

ថនៈ ស្ទឹងត្រែង ស្រុកអីពូ?

ធានៈ នៅស្រុក សេសាន ។

ថនៈ និយាយថារៀបការអីនេះដែរ តាមប្រពៃណី តាមអីដែរពូ ឬក៏យើងចាប់ដៃគ្នា?

ធានៈ មួយសារហ្នឹង ខ្ញុំយកគ្រួសារនៅកន្លែងពេទ្យរបស់រដ្ឋហ្នឹងណា ម្នោះហើយវាមានការតឹងតែងដែរ ទម្រាំបានគ្នា អ្នកយកហ្នឹងលុះត្រាពង្រាត់គ្នាចេញ ទាល់កូនស្រី កូនប្រុសស្រលាញ់ពេញ ចិត្តប្ដូរផ្ដាច់ជាមួយគ្នាបានៗ ។ កាលជំនាន់ខ្ញុំធូរស្រាលតិច ដោយមុនហ្នឹងខ្ញុំនៅជាមួយឈ្មោះនឹងឯង គាត់ជាមេបញ្ជាកានៅកងពលហ្នឹងគាត់ទទួលគណៈសមរភូមិមួយផ្នែកដែរ ដល់ចឹងត្រូវជាប្អូនថ្លៃគាខៀវហ្នឹង ដល់ចឹងទៅក៏គាត់ផ្ញើអន្តរាគមន៍តាមគ្រួសារគាត់ចឹងទៅ យកទៅឲ្យបងគាត់ បងគាត់មកក៏រៀបចំឲ្យទៅ ។

ថនៈ សព្វថ្ងៃកូនប៉ុន្មាននាក់ដែរទៅ?

ធានៈ កូនប្អូននាក់ប្រុសពីរ ស្រីពីរ ។

ថនៈ បានរៀនដែរពូ?

ផានៈ បានរៀនទាំងអស់ ។ ប៉ុនគ្រាន់តែថាបានតែមួយទេ បានសញ្ញាប័ត្របាក់ឌុប ហើយឥឡូវដាក់ពាក្យហ្នឹងទៅរៀនពេទ្យធ្មេប ប៉ុនមិនទាន់ដឹងដំណឹងថាយ៉ាងម៉េចៗទេ ។

ថនៈ ប្រុសអីពូ?

ផានៈ ស្រី ។

ថនៈ ហើយ៣នៅរៀន?

ផានៈ មួយនៅរៀនសាលាយើង បើពីរបង១ហ្នឹងឈប់ហើយ មួយយកគ្រួសារហើយ ។ អាមួយបងប្រុសហ្នឹងមិនទាន់យកគ្រួសារទេ នៅក្នុងបន្ទុកម៉ែឪ ។

ថនៈ ពូ មកស្នាក់នៅនេះដំបូងឆ្នាំប៉ុន្មានពូ?

ផានៈ នៅនេះជំនាន់យើងពីកិច្ចព្រមព្រៀងប៉ារីសឆ្នាំ ៩០,៩១ហ្នឹង ។

ថនៈ ចូលមកនេះតែម្តង?

ផានៈ មកនៅនេះ មកនៅនេះបានបន្តិចក៏វាយគ្នា ក៏ចេញពីនេះ ។

ថនៈ ទៅមកទៅវិញ?

ផានៈ បាទ! ទៅមកៗ ។

ថនៈ ចុះពូមកដល់នេះកាលដំបូង ពូមានរៀបចំជាភូមិ ជាឃុំ?

ផានៈ មុនដំបូងមានដែរ តែពីជំនាន់យើងខ្មែរក្រហមណា៎ ប៉ុន្តែភូមិឃុំហ្នឹងនៅក្នុងក្របខណ្ឌកងទ័ពគ្រប់គ្រងទេ ព្រោះអីចំភូមិនេះគឺគ្រាន់តែឲ្យគ្រប់គ្រងមីង១គ្រួសារកងទ័ពដែលត្រូវទៅសមរភូមិមុខដែលឲ្យជួយកិច្ចការផ្សារនៅខាងក្រោយរៀបចំ ។ រៀបចំមានភូមិមានឃុំដែរ ជួយដល់ស្រុកដែរ ប៉ុនគ្រាន់តែថាជំនាន់ហ្នឹងក្តាប់រូបភាព(ស្តាប់ពំបាន) ។

ថនៈ សព្វថ្ងៃនេះភូមិឃុំអីវិញពូ?

ផានៈ ភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទដែរ ។

ថនៈ ឧត្តរមានជ័យ?

ផានៈ បាទ! ចឹងបានស្រុកមួយនេះ ភូមិថ្មីទាំងអស់ អត់មានភូមិចាស់ទេ ។

ថនៈ ចឹងពូ ចង់សួរពូមួយទៀត ដូចជាពូធ្លាប់ចូលបំរើជាមួយចលនាខ្មែរក្រហមតាំងពីមុនមក ហើយពូគិតថាវា របៀបថាជីវិតពូបានឆ្លងកាត់បទពិសោធន៍ណាស់ ហើយពូនិយាយថាបើប្រៀបធៀប និយាយថាពូ និយាយថាមិនបានចុះចូលវាខុសគ្នាយ៉ាងម៉េចដែរពូ នៅស្រុកគៀនស្វាយហ្នឹង ដែលពុំមែនជាស្រុកកំណើតហ្នឹង?

ធានៈ ប្រៀបធៀបជារាល់ថ្ងៃ ពីមុនចូលបម្រើកង ពេលចូលបម្រើកងទ័ពថាខ្លួនឯងមានម៉ែ មានឪ មានបង មានប្អូន មានកូន មានទឹក មានដី ដល់មកកចូលបម្រើកងទ័ព ស្រណោះបងប្អូន ស្រណោះឪពុកម្ដាយដែលបែកចេញ សូម្បីរំដោះ៧៥ហើយក្បែរផ្ទះសោះក៏គេពុំឲ្យទៅលេងដែរ ហើយដល់ពេលរៀបចំមកព្រំដែនភាគឦសាន រយៈប៉ុន្មានឆ្នាំក៏មិនដែលបានដឹងដំណឹងពីស្រុកភូមិ បងប្អូនអីដែរ ស្ងាត់រហូត មកដល់ជំនាន់កិច្ចព្រមព្រៀងទើបបានដឹងដំណឹងខ្លះ បានសរសេរ សំបុត្រទៅមក ប៉ុនអត់ដែលបានទៅលេងទេ ក្រោយសមាហរណកម្មហើយ៩៩ បានៗទៅលេង មានឪពុកស្លាប់មុនមួយឆ្នាំ ចឹងស្ដាយស្រណោះអ្នកមានគុណ ។

ថនៈ បកទៅវិញ! ដូចថាចង់សួរពូថែមបន្តិច ពេលពូមកនៅនេះនៅត្រពាំងប្រាសាទ ខាងអន្លង់វែងពីរហ្នឹងដូដថាមូលហេតុអីជាខ្មែរក្រហមដូចគ្នា ប៉ុន្តែមូលហេតុអីដូចជាថអត់ចុះសម្រុងគ្នាជាមួយហ៎ដូចគំនិតអីចឹងលោកពូ?

ធានៈ អាហ្នឹងជាធម្មតាទេ ធម្មតាការដឹកនាំដូចថាដឹកនាំស្នូលធំនៅអន្លង់វែង ដល់ចឹងខាងត្រពាំងប្រាសាទនេះហ៎នៅមានស្នូលដឹកនាំដែរ ប៉ុនគ្រាន់តែជាមែកជាធាងរបស់ខាងអន្លង់វែង ដល់ចឹងទៅជៀសមិនផុតពីបញ្ហាការខ្នក់ចិត្តរវាងពីមួយទៅមួយទេ ។

ថនៈ ខ្នក់ចិត្តម៉េចវិញពូ?

ធានៈ ខ្នក់ចិត្តដូចថា ការផ្គត់ផ្គង់ ដូចថាជំនាន់ខ្មែរក្រហមចឹងណា ។ ការផ្គត់ផ្គង់ប្រៀបធៀបដូចថាយើងឪពុកម្ដាយតែមួយចឹង ប៉ុន្តែដល់ពេលការផ្គត់ផ្គង់ធម្មតាឪពុកម្ដាយ ដល់តែកូនណាយកគ្រួសារមុន មុខតែផ្គត់ផ្គង់កូនហ្នឹងច្រើនហើយ ព្រោះគេនៅក្បែរដៃណា ដល់ចឹងហើយគេប្រៀបធៀបពីអន្លង់វែងទៅត្រពាំងប្រាសាទ ពីដើមដឹកនាំនៅអន្លង់វែង តាម៉ុកគាត់នៅអន្លង់វែង ដល់ចឹងគាត់មើលជុំវិញគាត់ហ្នឹង បញ្ហាការដោះស្រាយអីទូលំទូលាយជាង ខាងត្រពាំងប្រាសាទហើយ ។

ថនៈ ត្រពាំងប្រាសាទខាងណាដឹកនាំ?

ធានៈ ដល់ក្រោយមក វាតែមួយហ្នឹង! មានតែតាម៉ុកតែមួយហ្នឹង ចុះបើតាខៀវគាត់ស្លាប់បាត់ហើយ ។ ប៉ុនមកដល់សម័យយើងនេះធម្មតាទេគេកូនគេមានជាងយើងជារូម ហើយខាងត្រពាំងប្រាសាទគេទើបតែ កវែក កន្ឋាំង ប៉ុន្តែសមាហរណកម្មវាថ្ងៃខែឆ្នាំតែមួយមែន ធម្មតាគេ មានទុនពីជំនាន់នោះមក ចង់មិនចង់ក៏គេមានលទ្ធភាពច្រើនជាយើងដែរ ។ ដល់ ចឹងទៅក្នុងការ រស់នៅវាចេះតែលំអៀងឃើញគេមានចឹងទៅ ឯងអត់ចេះតែមានការពេបជ្រាយលិចកើតចឹង ជៀសអត់ផុតទេ ។ សេចក្ដីទំនាស់ ទាស់ទែងខាងផ្លូវចិត្ត ។

ថនៈ ខាងនេះ! គាត់ចូលចិត្តខាងប៉ុល ពតច្រើនជាង ឬយ៉ាងម៉េចពូ ខាងត្រពាំងប្រាសាទ?

ធានៈ ខាងប៉ុល ពត ខាងដឹកនាំជំនាន់ហ្នឹងវាជារឿងការផុតអស់ទៅហើយ ព្រោះអីជំនាន់ហ្នឹង គាត់គ្រប់គ្រងដែរតែធ្វើឲ្យកង់ទ័ព ធ្វើឲ្យប្រជាជនវេទនា រឿងដីធ្លីក៏គ្នាបាត់បង់ដែរ ។

ថនៈ ប៉ុល ពត ហ្នឹង?

ធានៈ បាទ! ជារឿងមួយរបស់គាត់ដែរ ប៉ុន្តែថាឲ្យជាចំណង់ចំណូលដូចថានិយាយរួមឲ្យតែដឹកនាំ (ស្តាប់ពុំបាន) ចូលក្នុងរដ្ឋាភិបាលគ្រប់គ្រង ដូចម៉ែដូចឪ ។ គ្រាន់តែថាចូលក្នុងរដ្ឋាភិបាលនេះ បើយើងសេចក្តីសុខវាមានច្រើន ប៉ុន្តែទុក្ខក៏វាខ្លះដែរចៀសមិនផុតទេ ធម្មតាទេ ដឹកនាំខាងលើ មិនមែនចង់ឲ្យកូនក្រុមទាំងអស់គ្នាទេ ហើយបើមានស្មើរគ្នាក៏អត់ស្មើរគ្នាដែរ ពីណាប្រឹងទៅក៏បាន ទៅ ពីណាមិនប្រឹងក៏តាមជាក់ស្តែង ព្រោះយើងមើលម្រាមដៃវាអត់ស្មើរគ្នាផង នៅមានខ្ពស់ មានទាប ។

ថនៈ ចុះពេលដែលព្រឹត្តិការណ៍ដែលឈ្លោះវាយគ្នានៅអន្លង់វែងហ្នឹង ពូនៅហ្នឹងដែរ ឬក៏ពូនៅឯណា?

ធានៈ ហ្ហ៎! មួយសារនៅព្រឹត្តិការណ៍នៅអន្លង់វែងដែលជាមួយប៉ុល ពត តាម៉ុក ហេ៎?

ថនៈ បាទ!

ធានៈ ខ្ញុំនៅអន្លង់វែងហ្នឹងដែរតា ។

ថនៈ ពូ! មានដឹងព្រឹត្តិការណ៍អីខ្លះ?

ធានៈ កាលថ្ងៃ៥ ថ្ងៃ៦ ខាងក្នុងវាយខាងក្នុង ប៉ុន្តែមិនដឹងជារឿងអីរបៀបយ៉ាងណាទេ ។

ថនៈ ខ្ញុំចង់និយាយថាពេលតាម៉ុក ជាមួយប៉ុល ពត គាត់ថាឈ្លោះគ្នា?

ធានៈ ព្រោះអីជំនាន់ហ្នឹងដែលក្រោយពីអ៉ំឲ្យថ្នាក់ដឹកនាំចំនួនពរូប ដើម្បីទៅទំនាក់ទំនងជាមួយខាងលិច ដូចជាខាងម៉ាឡៃ បៃលិនអីចឹងទៅណា ដើម្បីអូសទាញកម្លាំងហ្នឹងចេញមកធ្វើអតីតខ្មែរក្រហម វិញ ។ និយាយមួយជំនាន់ហ្នឹង ប៉ុល ពត គាត់អ្នកជំរុញរដ្ឋាភិបាលកិច្ចព្រមព្រាងទីក្រុងប៉ារីស ណា៎ ដល់គាត់ពីនោះមកគាត់ក៏មកនេះទៀត ដើម្បីជំរុញចូល ដល់ពេលថ្ងៃរៀបចំបោះឆ្នោត ហ្នឹង គាត់រៀបចំកម្លាំងវាយ ដល់ចឹងមិនរដ្ឋាភិបាលដាក់ក្រៅច្បាប់ អន្តរជាតិ ដាក់ក្រៅច្បប់ ចុះបើយើងឲ្យចូលក្នុងរដ្ឋាភិបាលហើយ ទោះបីថាយើងយ៉ាងណាៗ ថាឲ្យយើងចូលរដ្ឋាភិបាល ទៅ វាស្របច្បាប់មួយហើយ អត់ចូលវានៅក្រៅច្បាប់ហើយ ។

ថនៈ គាត់ឲ្យបីនាក់ហ្នឹង ពីណាខ្លះពូ?

ផានៈ មានតាម៉ុក, តាខៀវ ហៅសុន សេន ហើយហ្នឹងមាន អ៊ីនោះមួយទៀត អ៊ីហែប តែខ្ញុំអត់ស្គាល់ច្បាស់ដែរ ឮតែឈ្មោះទេ ប៉ុនដល់ចូលខាងនោះគេថាឯងប្រញាប់ទៅវិញទៅ ព្រោះអីឥឡូវ បងប្អូនកូនចៅចូលក្នុងរដ្ឋាភិបាលហើយ គេមិនអាចងាកក្រោយវិញទេ ។

ថនៈ គាត់បញ្ចុះបញ្ចូលកុំឲ្យចូល ឬយ៉ាងម៉េច?

ផានៈ មុនដំបូង! គាត់រុញឲ្យចូលតាប៉ុល ពត ដល់ក្រោយឡើង គាត់ឲ្យរៀបចំកម្លាំងដឹកនាំបីនាក់នោះទៅដើម្បីអូសទាញកុំអាលចូលក្នុងរដ្ឋាភិបាល ខាងនោះទៅគេថា តាអើយដំណើរទៅមុខអត់ថយក្រោយវិញទេ តានោះក៏ចេញទៅវិញទៅ ដល់មកដល់នេះគេក៏ចាប់ផ្ដើម ដឹកនាំខាងលើៗហ្នឹង ក៏មានកើតខ្វែងគំនិតគ្នា ចាប់ ប៉ុល ពត សម្លាប់តាខៀវចោល ដល់ចឹងតាម៉ុកហ្នឹងឆ្មៀតចុះមកក្រោមនេះ ដល់ចឹងតាម៉ុក គាត់ឆ្មៀតយកឱកាសហ្នឹងធ្វើរដ្ឋប្រហារ ប៉ុល ពតទៅ ។ ហើយថ្ងៃ៥ ថ្ងៃ៦ហ្នឹងតាមខ្ញុំក្ដាប់បានក្នុងក៏វាយក្នុងដែរ ក្រៅនេះក៏វាយក្រៅដែរ ប៉ុនមិនដឹងជារបៀបយ៉ាងម៉េច ខ្ញុំដូចជាឆ្ងល់ចំនុចហ្នឹងមួយដែរ(សើច) ។

ថនៈ ហេតុអ្វីបានជាប៉ុល ពត ឲ្យសម្លាប់តាសុន សេន តាមពូ?

ផានៈ ខ្ញុំក្ដាប់ពុំបានដែររឿងខាងលើ យើងជាសមាជនខាងក្រោម មួយសារហ្នឹងកំណើតកូនខ្ញុំអាមួយប្រុសនេះឯង ទើបកើតបានមួយថ្ងៃ ព្រឹត្តិការណ៍ចឹងទៅ ដល់ចឹងទៅគេថាឥឡូវពូនទៅ ព្រោះអីខ្ញុំនៅកណ្ដាលគេណា ។

ថនៈ ពូនៅណាគេ កាលហ្នឹង?

ផានៈ ខាងតារឿន០៥ គាត់នៅខាងកើត ហើយកម្លាំងតាម៉ុក នៅខាងលិច ហើយពួកខ្ញុំនៅប្រលោះកណ្ដាលអូរបុស្សី ដល់ចឹងកម្លាំងអន្ដភាពខ្ញុំវានៅក្រោយវាមានចំនួនច្រើន ដល់ចឹងទៅពីខាងកើតវាទិសដៅចាប់កម្លាំងខាងពួកខ្ញុំ៣០២ហ្នឹងណា៎ ពីខាងលិចមកថាធ្វើម៉េចចាប់៣០២ឲ្យបានពួកខ្ញុំ អត់មានលំអៀងទៅខាងណាទេ នាំគ្នាគេចដេកព្រៃ តែប្រពន្ធទេដេកផ្ទះ ។ ប៉ុន្ដែបើពីកើតក៏ដោយពីលិចក៏ដោយ បើសិនធ្វើបាបប្រពន្ធកូនក៏មានផ្ទុះកាំភ្លើងដែរ ប៉ុន្ដែជាក់ស្ដែងគេមកអត់បានផ្ទុះអាវុធអីទេ ។

ថនៈ អត់មានបានវាយគ្នាទេ?

ផានៈ បាទ! អត់ទេ ។ វាយតែខាងលើៗ គេវាយតែខាងលើភ្នំទេ ។

ថនៈ ចុះហើយម៉េចបានចាប់ដូចសារឿនអីបានទៅ វាយព័ទ្ធចាប់?

ផានៈ ចុះបើប៉ុល ពតគាត់មិនឲ្យវាយ គាត់ថាជាតិខ្មែរគ្នាឯងរួមការងារជាមួយគ្នាពីណាពីណើមក ដល់ចឹងឲ្យតាម៉ុកចាប់ដឹកនាំពីខាងកើត កម្លាំងប៉ុល ពត ហ្នឹងកាត់ទោសអស់ទៅ ។

ថនៈ ចុះកាលកាត់ទោសពូនៅដែរ?

ធានៈ អត់យល់ទេ ព្រោះអី!

ថនៈ កាលនោះពូចូលរួមទេ?

ធានៈ អត់ទេ! តាម៉ុក ហៅខ្ញុំ ។

ថនៈ ចុះខ្ញុំឃើញមានប្រជាជនឃើញមានអីជាវីដេអូ មានប្រជាជនចូលរួម?

ធានៈ ប្រជាជននៅក្បែរៗហ្នឹង ។

ថនៈ យ៉ាងម៉េចបានពូមកនៅខាងអន្លង់វែងខាងត្រពាំងប្រាសាទ?

ធានៈ ព្រោះអីមួយសារជំនាន់កិច្ចព្រមព្រៀងប៉ារីសហ្នឹង មួយសារហ្នឹងខ្ញុំនៅខាងលើ អាទំនប់ពោធិ៍ជីកហ្នឹងណា ដល់តាទប់ទំនប់ចឹងទៅ ហាក់បីដូចជាទៅនៅលើកោះចឹងទៅ ដល់ចឹងមិនដឹងជាដី បង្កបង្កើនផលអីរបៀបម៉េចទេ ដល់ចឹងក៏សុំមតិគាត់មេហ្នឹងណា! មេឈ្មោះ ឆន មេបញ្ជាការ កងពល៨០២ហ្នឹងក៏សុំដល់តា ក៏ថាឥឡូវបើចឹងឯងក៏ចេញទៅនៅតាមផ្លូវក្រហមទៅ ប៉ុន្តែ ទិសដៅគាត់អត់ឲ្យហួសមកត្បូងនេះទេ ពីទិសគាត់នេះត្រឹមភូមិឈូកសយើងទៅចេះវិញ ប៉ុនដល់ពួកខ្ញុំមក ដល់មកឃើញសុទ្ធតែដីព្រិច ដល់ចឹងមិនដឹងម៉េចដាំដុះបានស៊ីទេ ក៏នាំគ្នាមកនៅតាមនេះ ។

ថនៈ គាត់អត់ថាអីដែរ?

ធានៈ ទេ! គាត់ថាណា ៗ មកនៅដំបូង គាត់ប្រមាថដុតផ្ទះ ដុតសម្បែងមាំណាំថា ពួកអាក្បត់ជាតិ ពួកអាបំផ្លាញព្រៃឈើ ដល់មកដល់យូរៗទៅបង្កបង្កើនផលបានដាំចេក ដាំអំពៅបានចឹង ក៏គាត់សរសើរហៅមកវិញ ៗ និយាយរួម គាត់មានគំនិតមិនឲ្យកាប់ព្រៃឈើទេ អាហ្នឹងគំនិតតាម៉ុកណា ៗ គាត់ថាហែងមកនៅច្បាស់ជាអស់ហើយព្រៃឈើហ្នឹង គ្មានសល់ទេអាពួកឯងក្បត់ជាតិនោះ ៗ បើមិនកាប់ធ្វើម៉េចបានដំណាំ បានស្រូវដាំដុះហូប ៗ ហើយមុនដំបូងនោះគាត់មកពេលណា ក៏គាត់ប្រមាថកាព្យទាន អារឿងដុតផ្ទះដែរ ប៉ុន្តែគាត់បានតែថាទេ គាត់មិនដែលទៅដុតផ្ទះបងប្អូនទេ នៅពេលដាំចេកដាំអំពៅបានចេះតែកាប់ផ្ញើរគាត់ធម្មតាដឹកនាំ គោរពដូចម៉ែដូចឪ ពេលបានភោគផលហើយ ចេះតែនឹកគុណម៉ែឪវិញទៅ ចេះតែផ្ញើគាត់ហូបទៅ ដល់ចឹងគាត់សរសើរវិញ ៗ ដល់ចឹងពេលរៀនសូត្រហៅដឹកនាំទៅរៀនសូត្រចឹង គាត់លើកឡើងអាប្រសប់ ពួក៨០២ គេបានចេកបានអំពៅ បានចេកល្ហុងស៊ីសម្បើមណាំ ពួកហែងស៊ីៗដោយសារគេហ្នឹងណា ផ្ញើរមកទៅជាម្យ៉ាងវិញចឹងទៅ ។

ថនៈ ចឹងដូចជាខ្ញុំអត់មានអីសួរពូបន្ថែមទៀតទេ ។ ខ្ញុំអគុណពូច្រើនចំណាយពេលឲ្យខ្ញុំសម្ភាសន៍រហូត ។

ធានៈ   អគុណក្មួយដែរ ដែលបានមកសម្ភាសន៍ដើម្បីមកសួរសំណេះសំណាលដែរ អគុណ ។

ចប់